ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការធ្វើបច្ចុប្បន្នភាពសេវាអប់រំកុមារតូច ទៅរដ្ឋបាលក្រុង/ស្រុក ក្នុងខេត្តបាត់ដំបង

## Situations of updating early childhood education to municipal/district administration in Battambang province

យ៉ុង សុផានា
Yong Sophana

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ស្ថានភាពនៃការធ្វើបច្ចុប្បន្នភាពសេវាអប់រំកុមារតូច ទៅរដ្ឋបាលក្រុង/ស្រុក ក្នុងខេត្តបាត់ដំបង

# Situations of updating early childhood education to municipal/district administration in Battambang province


យ៉ុង សុផានា

Yong Sophana


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២


គ្រូដឹកនាំគោល ៖ បណ្ឌិត ឈន ថន

គ្រូដឹកនាំរង ៖ បណ្ឌិត មឿន លិនណា

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា **«ស្ថានភាពនៃការធ្វើបច្ចុប្បន្នភាពសេវាអប់រំកុមារតូច នៅរដ្ឋបាលក្រុង-ស្រុក ក្នុងខេត្តបាត់ដំបង»** សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបាន ស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទ ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខា**

**យ៉ុង សុផានា**

# លិខិតបញ្ជាក់

**បណ្ឌិត ឈន ថន** ជាគ្រូដឹកនាំគោល

**បណ្ឌិត មឿន លិនណា** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **យ៉ុង សុផានា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្តីពី«**ស្ថានភាពនៃការធ្វើបច្ចុប្បន្នភាពសេវាអប់រំកុមារតូចនៅរដ្ឋបាលក្រុង-ស្រុក ក្នុងខេត្តបាត់ដំបង**» ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២២

| | |
|---|---|
| ........................................ | ........................................ |
| **បណ្ឌិត ឈន ថន** | **បណ្ឌិត មឿន លិនណា** |
| គ្រូឧទ្ទេស វិទ្យាស្ថានជាតិអប់រំ | គ្រូឧទ្ទេស វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ និងការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣៧០២៥ អយក.ខុទ្ទន

(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំៈ

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អ៊ែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វេជអ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ:..៣៧២៦..អយក.ទុន

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គីមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ ប៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សូគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ថាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ស្មី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

# លិខិតអនុញ្ញាត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

គោរពជូន
ឯកឧត្តមបណ្ឌិតនាយក វិទ្យាស្ថានជាតិអប់រំ

| | | |
|---|---|---|
| អនុញ្ញាតឱ្យនិស្សិតឈ្មោះ | ៖ | យ៉ុង សុផានា<br>YONG SOPHANA |
| ប្រធានបទស្រាវជ្រាវ | ៖ | **ការធ្វើបច្ចុប្បន្នភាពសេវាអប់រំកុមារតូច ទៅរដ្ឋបាលក្រុង-ស្រុក ក្នុងខេត្តបាត់ដំបង** |
| ដើម្បីចូលរួម | ៖ | ការពារនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ |
| កាលបរិច្ឆេទការពារសាកល្បង | ៖ | ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០២២ |
| ទីកន្លែង | ៖ | វិទ្យាស្ថានជាតិអប់រំ |

យើងខ្ញុំជាសាស្ត្រាចារ្យដឹកនាំ និងដឹកនាំរង ពិតជាបានអនុញ្ញាតឱ្យ និស្សិតមានឈ្មោះខាងលើបានចូលរួមការពារនិក្ខេបបទបញ្ចប់ ដើម្បីបំពេញក្របខ័ណ្ឌការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ឆ្នាំសិក្សា ២០២០-២០២២ តាមការកំណត់របស់វិទ្យាស្ថានជាតិអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា។

ថ្ងៃអង្គារ ៨រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២

**សាស្ត្រាចារ្យដឹកនាំ**

Chhornthan

បណ្ឌិត ឈន ថន

**សាស្ត្រាចារ្យដឹកនាំរង**

បណ្ឌិត មឿន លិនណា

# មូលន័យសង្ខេប

ការសិក្សានេះ សិក្សាពីការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក ដែលជាសេវាអប់រំអាទិភាពក្នុងកម្មវិធីកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំមុខងារ តួនាទីភារកិច្ចនៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក។ ការអប់រំកុមារតូចសំដៅលើការអភិវឌ្ឍសមត្ថភាពគ្រប់ជ្រុងជ្រោយរបស់កុមារផ្នែកសង្គមអារម្មណ៍ ផ្លូវចិត្ត ផ្នែកចំណេះដឹង និងផ្នែករាងកាយ ដោយការយកចិត្តទុកដាក់លើការបញ្ចូលភាពត្រៀមខ្លួនរួចជាស្រេចរបស់កុមារតូចសម្រាប់ការចូលរៀននៅសាលាបឋមសិក្សា។ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ រួមមាន(១) សិក្សាពីការគ្រប់គ្រង និងការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក និង(២) ស្វែងយល់ពីផលជះនៃការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់វិធីសាស្ត្របែបចម្រុះ ដែលជាការរួមបញ្ចូលគ្នានៃវិធិសាស្ត្រស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ។ ការសិក្សានេះ បានប្រើប្រាស់ទិន្នន័យទី១ (Primary Data)។ កម្រងសំណួរ និងសម្ភាសន៍ផ្ទាល់ ដែលជាឧបករណ៍ប្រមូលទិន្នន័យ ត្រូវបានប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យ។ វិធីសាស្ត្រវិភាគទិន្នន័យនៃការសិក្សាស្រាវជ្រាវ រួមមានវិធីសាស្ត្រវិភាគពណ៌នា(Content Analysis)សម្រាប់ការវិភាគទិន្នន័យបែបគុណវិស័យ និងវិធីសាស្ត្រវិភាគបកស្រាយស្ថិតិ (Descriptive Statistics Analysis) សម្រាប់ការវិភាគទិន្នន័យបែបបរិមាណវិស័យ។ ការសិក្សានេះ បានជ្រើសរើសសំណាកចំនួន៤២៨នាក់ (ស្រី ២៦៦)។

ការសិក្សាស្រាវជ្រាវបានបង្ហាញថា ការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុកមានសារៈសំខាន់ណាស់សម្រាប់ការបង្កើតយន្តការ និងគោលនយោបាយអប់រំ លើកកម្ពស់គុណភាពអប់រំ និងអភិវឌ្ឍវិធីសាស្ត្របង្រៀននិងរៀន។ ការផ្ទេរសេវាអប់រំអប់រំកុមារតូចផ្ទេរទៅរដ្ឋបាលក្រុង/ស្រុក បានពង្រឹងការងារគ្រប់គ្រងសាលារៀន បង្កើនលទ្ធភាពចុះឈ្មោះចូលរៀន និងបង្កភាពងាយស្រួលដល់ការចូលរៀនរបស់កុមារ។ ការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក គឺជាការបង្វិតសេវាអប់រំទៅជិតអ្នកទទួលសេវាអប់រំ ការបង្កើនការចុះឈ្មោះចូលរៀនរបស់កុមារ និងការផ្តល់ភាពងាយស្រួលដល់កុមារចូលរៀន។

ការសិក្សាស្រាវជ្រាវនេះ បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនសម្រាប់ការធ្វើកំណែទម្រង់កម្មវិធីអប់រំនៅថ្នាក់ក្រោមជាតិ។ សារៈប្រយោជន៍ទាំងនេះ រួមមានការជំរុញការចូលរួមរបស់មាតាបិតា/អាណាព្យាបាលរបស់កុមារ និងសហគមន៍ក្នុងការពង្រឹងសមត្ថភាពចំណេះដឹងកុមារសម្រាប់ការចូលរៀន និងការអនុវត្តសេវាអប់រំកុមារតូចមានការអភិវឌ្ឍ និងស្ថេរភាពដែលចូលរួមក្នុងការងារបែបវិមជ្ឈការ និងសហវិមជ្ឈការ។

# Abstract

This study examines the transfer of early childhood education services to the municipal / district administration, which is a priority education service in the decentralization and co-decentralization reform program of the Ministry of Education, Youth and Sports to organize the functions, roles, and responsibilities in the municipal/district education, youth and sports offices. Early childhood education refers to the development of a child's all-round social, emotional, psychological, cognitive, and physical abilities by focusing on integrating young children's readiness for primary school enrollment. The objectives of this research include (1) to examine the management and transfer of early childhood education services to the municipal / district administration and (2) to investigate the impact of transferring the early childhood education services to the municipal/district administration.

This research study employed the mixed research-methods, which was a combination of qualitative and quantitative research methods. This study used primary data. Questionnaire and personal interviews, regarding as the data collection tools, were used for data collection. Data analysis methods of this research study included Content Analysis for qualitative data analysis and Descriptive Statistics Analysis for quantitative data analysis. This study selected 428 samples (including 266 females).

Research showed that the transfer of early childhood education services to municipal / district administrations was critical for conducting the education mechanisms and policies, improving the education quality, and developing the teaching and learning methods. Transfer of early childhood education services to municipal/district administrations helped strengthening the school management, increased the enrollment, and facilitated children's access to education. The transfer of early childhood education services to the municipal/district administration brought education services closer to the recipients, increased children's enrollment, and made it easier for children to attend school.

This research provided many benefits for sub-national education program reform. These benefits included promoting the involvement of children's parents/guardians and community in strengthening children's knowledge and capacity for school accessing and implementing the developmental and stable early childhood education services involved in decentralized and co-decentralized work.

# លិខិតថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះលោកឪពុកអ្នកម្ដាយ ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងដល់រូបកូនឱ្យបានទទួលការសិក្សារហូតរូបកូនមានថ្ងៃនេះ និងសូមថ្លែងអំណរគុណយ៉ាងច្រើនបំផុតដល់ឧត្តមភរិយាជាទីស្រឡាញ់របស់ខ្ញុំ កូនៗ ជាទីស្រលាញ់ និងមិត្តភក្ដិ ដែលបាន គាំទ្រ និងលើកទឹកចិត្តក្នុងពេលសិក្សានេះ។

ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះគណៈកម្មការគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោក សាស្ត្រាចារ្យទាំងអស់ ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុត មកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេសខ្ញុំបាទសូមគោរពថ្លែងអំណរគុណជូនចំពោះបណ្ឌិត **ឈុន ថន** សាស្ត្រាចារ្យដឹកនាំសរសេរនិក្ខេបបទ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពិនិត្យវាយតម្លៃ ជួយណែនាំ និងផ្ដល់យោបល់ណែនាំដល់រូបខ្ញុំបាទក្នុងការសរសេរនិក្ខេបបទស្ដីពី**ស្ថានភាពនៃការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង-ស្រុក ក្នុងខេត្តបាត់ដំបង**។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់បណ្ឌិត **មឿន លិនណា** សាស្ត្រាចារ្យដឹកនាំរង ដែលតែងតែផ្ដល់នូវកម្លាំងចិត្ត ចំណេះដឹង ចែករំលែកបទពិសោធដល់រូបខ្ញុំ ព្រមទាំងមិត្តរួមថ្នាក់ជំនាន់ទី៩ និងមិត្តរួមការងារដែលតែងតែផ្ដល់នូវកម្លាំងចិត្ត ធ្វើឱ្យរូបខ្ញុំទទួលបានជោគជ័យនាថ្ងៃនេះ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំមន្ទីរ, មន្ត្រីជំនាញ ការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តបាត់ដំបង ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក នៃរដ្ឋបាលក្រុង/ស្រុកទាំង១៤ នៃខេត្តបាត់ដំបង គណៈគ្រប់គ្រងសាលា ថ្នាក់ លោកគ្រូ អ្នកគ្រូ តាមសាលាគោលដៅទាំងអស់ដែលបានអនុញ្ញាត និងចូលរួមសហការ ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ លោក លោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


សេចក្តីអះអាងរបស់បេក្ខជន ........ I

លិខិតបញ្ជាក់ ........ II

លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ និងការការពារនិក្ខេបបទ ........ III

លិខិតអនុញ្ញាត ........ VII

មូលន័យសង្ខេប ........ VIII

ABSTRACT ........ IX

លិខិតថ្លែងអំណរគុណ ........ X

មាតិកា ........ XI

បញ្ជីរូបភាព/តារាង ........ XV

បញ្ជីនៃសញ្ញា/អក្សរកាត់ ........ XVI

ជំពូក ១ ........ ១

សេចក្តីផ្តើម ........ ១

១.១. លំនាំនៃការស្រាវជ្រាវ ........ ១

១.២ បញ្ហានៃការស្រាវជ្រាវ ........ ២

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ៤

១.៤ សំណួរនៃការស្រាវជ្រាវ ........ ៤

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៥

១.៦ ដែនកំនត់នៃការស្រាវជ្រាវ ........ ៥

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៦

ជំពូក ២ ........ ៧

រំលឹកទ្រឹស្តី ........ ៧

២.១ និយមន័យនៃពាក្យគន្លឹះ.....ៗ
២.១.១ ការធ្វើបច្ចុប្បន្នភាពសេវាអប់រំ .....ៗ
២.១.២ អប់រំកុមារតូច .....៨
២.២ ការផ្តល់សេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា.....៩
២.២.១ សេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សាសាធារណៈ និងឯកជន .....៩
២.២.២ សេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សាសហគមន៍.....១២
២.៣ កម្មវិធីសិក្សាការអប់រំកុមារតូចនៅមត្តេយ្យសិក្សា.....១៣
២.៣.១ កម្មវិធីសិក្សាមត្តេយ្យសិក្សាសាធារណៈ និងឯកជន .....១៤
២.៣.២ កម្មវិធីសិក្សាមត្តេយ្យសិក្សាសហគមន៍.....១៥
២.៤ ការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា.....១៦
២.៤.១ ការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សាសាធារណៈ និងឯកជន .....១៨
២.៤.២ ការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សាសហគមន៍.....២២
**ជំពូក ៣** .....២៤
**វិធីសាស្ត្រស្រាវជ្រាវ** .....២៤
៣.១ ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ.....២៤
៣.២ ការជ្រើសរើសសំណាក.....២៤
៣.៣ ប្រភពទិន្នន័យ.....២៥
៣.៤ ការប្រមូលទិន្នន័យ.....២៥
៣.៤.១ កម្រងសំណួរ .....២៥
៣.៤.២ សំណួរសម្ភាសន៍.....២៥
៣.៥ ការវិភាគទិន្ន័យ.....២៦
៣.៥.១ ការវិភាគកម្រងសំណួរ.....២៦
៣.៥.២ ការវិភាគសម្ភាសន៍ .....២៧
៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ.....២៧

**ជំពូក ៤**......................................................................................................២៨
**លទ្ធផល និងការពិភាក្សា**......................................................................................២៨
៤.១ លទ្ធផលស្រាវជ្រាវ......................................................................................................២៨
៤.១.១ ការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក ..........................................២៨
៤.១.២ ការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា ...............................................៣១
៤.១.៣ ផលជះនៃការផ្ទេរអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក........................................៣៤
៤.២ ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ.......................................................................................៣៧
៤.២.១ យន្តការនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង-ស្រុក .................................. ៣៧
៤.២.២ យុទ្ធសាស្ត្រនៃការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា ..........................៣៨
៤.២.៣ សារៈសំខាន់នៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក ...........................៣៩
**ជំពូក ៥**...................................................................................................... ៤០
**សេចក្តីសន្និដ្ឋាន និងសំណូមពរ** ......................................................................... ៤០
៥.១ សេចក្តីសន្និដ្ឋាន.......................................................................................................៤០
៥.២ អនុសាសន៍..............................................................................................................៤១
៥.២.១ ប្រសិទ្ធភាពនៃការផ្ទេរសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា ..................................... ៤១
៥.២.២ ការលើកកម្ពស់គុណភាពអប់រំនៅមត្តេយ្យសិក្សា ................................................. ៤១
៥.៣ សំណូមពរ.................................................................................................................៤២
**ឯកសារយោង**.................................................................................................... ៤៣
**ឧបសម្ព័ន្ធ** ....................................................................................................... ៤៨
ឧបសម្ព័ន្ធទី ១ ៖ លិខិតចាត់តាំងគ្រូដឹកនាំគោល និងគ្រូដឹកនាំរង សម្រាប់ការសរសេរនិក្ខេបបទ និងលិខិតបង្គាប់ការគណៈកម្មការការពារនិក្ខេបបទបញ្ចប់ .........................................................................៤៨
ឧបសម្ព័ន្ធទី ២ ៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា.........................................................៥៤
ឧបសម្ព័ន្ធទី ៣ ៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ..........................................៥៥

ឧបសម្ព័ន្ធទី ៤ ៖ កម្មវិធីចុះប្រមូលទិន្នន័យ............................................................................................................៥៦

ឧបសម្ព័ន្ធទី ៥ ៖ កម្រងសំណួរសម្រាប់បំពេញ.......................................................................................................៥៧

ឧបសម្ព័ន្ធទី ៦ ៖ កម្រងសំណួរសម្ភាសន៍ .............................................................................................................៦០

ឧបសម្ព័ន្ធទី ៧ ៖ ចំនួនភាគសំណាក និងឈ្មោះសាលា ថ្នាក់ មត្តេយ្យសិក្សាដែលត្រូវចុះប្រមូលទិន្នន័យស្រាវជ្រាវ...........................................................................................................................................................៦៦

# បញ្ជីរូបភាព/តារាង


តារាង ៤.១ ទស្សនៈគណៈគ្រប់គ្រងចំពោះការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក ....................... ២៩

តារាង ៤.២ ទស្សនៈគ្រូបង្រៀនចំពោះការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក ............................. ៣០

តារាង ៤.៣ ទស្សនៈមាតាបិតា ឬអ្នកអាណាព្យាលសិស្សចំពោះការផ្ទេរសេវាអប់រំកុមាតូច
ទៅរដ្ឋបាលក្រុង/ស្រុក........................................................................................................ ៣១

តារាង ៤.៤ ទស្សនៈគណៈគ្រប់គ្រងចំពោះការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា------------------- ៣២

តារាង ៤.៥ ទស្សនៈគ្រូបង្រៀនចំពោះការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា ..............................៣៣

តារាង ៤.៦ ទស្សនៈមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សចំពោះការអប់រំកុមារតូចនៅមត្តេយ្យសិក្សា........... ៣៤

តារាង ៤.៧ ទស្សនៈគណៈគ្រប់គ្រងចំពោះផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក.......... ៣៥

តារាង ៤.៨ ទស្សនៈគ្រូបង្រៀនចំពោះផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក ................ ៣៦

តារាង ៤.៩ ទស្សនៈមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សចំពោះផលជះនៃការផ្ទេរសេវាអប់រំកុមារតូច
ទៅរដ្ឋបាលក្រុង/ស្រុក.........................................................................................................៣៧

# បញ្ជីនៃសញ្ញា/អក្សរកាត់

| | | |
|---|---|---|
| ក្រសួងអយក | : | ក្រសួងអប់រំ យុវជន និងកីឡា |
| ក្រសួងសហវ | : | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| នា.អកត. | : | នាយកដ្ឋានអប់រំកុមារតូច |
| នា.បបវ. | : | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |

# ជំពូក ១

# សេចក្តីផ្តើម

# ជំពូក ១

# សេចក្តីផ្តើម

ជំពូកទី១ បានបង្ហាញពីលំនាំនៃការស្រាវជ្រាវ នៃប្រធានបទ «*ស្ថានភាពនៃការផ្ទេរបច្ចុប្បន្នភាពសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង-ស្រុក ក្នុងខេត្តបាត់ដំបង*»។ ជំពូកនេះ ក៏បានបង្ហាញ បញ្ហានៃការស្រាវជ្រាវ គោលបំណងស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

## ១.១. លំនាំនៃការស្រាវជ្រាវ

ការសិក្សានេះមានគោលបំណងសិក្សា និងស្វែងយល់ពីការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។ សេវាអប់រំកុមារតូចនៅកម្ពុជា គឺសំដៅការអប់រំកុមារតូចនៅតាមសាលាមត្តេយ្យសិក្សាសាធារណៈ សាលាមត្តេយ្យសិក្សាឯកជន សាលាមត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ/អប់រំមាតាបិតា។ ការពង្រីកលទ្ធភាពនៃការផ្តល់សេវាអប់រំកុមារតូច ត្រូវបានធ្វើឡើងនៅតាមសាលាមត្តេយ្យសិក្សាសហគមន៍ ជាពិសេសនៅតាមជនបទ។ គុណភាពអប់រំក៏ជាប្រការដែលត្រូវការផ្តោតការយកចិត្តទុកដាក់បន្ថែមលើការពង្រីកទំហំសេវាអប់រំ។ សេវាអប់រំកុមារតូចជាសេវាអប់រំអាទិភាពមួយនៅក្នុងកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការ ដែលក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំមុខងារ តួនាទីភារកិច្ចការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ដើម្បីផ្ទេរទៅរដ្ឋបាលក្រុង/ស្រុក (ក្រសួងអយក, ២០១៩)។

ការអប់រំកុមារតូច ត្រូវបានកំណត់ក្នុងមុំទី «ការអភិវឌ្ឍធនធានមនុស្ស» ចំណុចទី២ -ការបន្តវិនិយោគលើការកសាងសាលាបឋមសិក្សាបានដល់ភូមិ និងអនុវិទ្យាល័យឱ្យបានគ្រប់ឃុំតាមការចាំបាច់ផ្អែកលើស្ថានភាពសង្គមសេដ្ឋកិច្ច, ការបន្តផ្តល់អាហារូបករណ៍ និង មធ្យោបាយទ្រទ្រង់ចាំបាច់ផ្សេងៗទៀត ដល់សិស្សក្រីក្រ សិស្សស្ថិតនៅតំបន់ជួបការលំបាក និងសិស្សមានពិការភាព, ការរៀបចំយុទ្ធនាការផ្សព្វផ្សាយទូទាំងប្រទេស អំពីសារៈប្រយោជន៍នៃការអប់រំកម្រិតមូលដ្ឋាន, ការបង្កើនការវិនិយោគលើការអភិវឌ្ឍកុមារតូច និង ការបន្តបង្កើតថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាព, ព្រមទាំងជំរុញការរៀបចំឱ្យមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមដានព័ត៌មានសិស្សសំដៅផ្តល់កិច្ចអន្តរាគមន៍ឱ្យទាន់ពេលវេលាតាមគ្រប់មធ្យោបាយ ដើម្បីទប់ស្កាត់នូវការបោះបង់ការសិក្សារបស់សិស្សានុសិស្ស (យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា, ២០១៨-២០២៣)។

យុទ្ធសាស្ត្រចតុកោណនេះ បានបង្ហាញអំពីធន្ទះផ្នែកនយោបាយ ចំពោះការគាំពារ និងអភិវឌ្ឍន៍កុមារតូច នៅក្នុងព្រះរាជាណាចក្រកម្ពុជា របស់រាជរដ្ឋាភិបាល ដើម្បីចូលរួមអភិវឌ្ឍសេដ្ឋកិច្ច មុខរបរ សមធម៌ និងប្រសិទ្ធផល។ ពិភពលោកបានបោះជំហានចូលក្នុងយុគសម័យថ្មី មានឈ្មោះថា យុគសម័យឌីជីថល និងបដិវត្តឧស្សាហ៍កម្មទី៤។ យុគសម័យនេះ ទាមទារនូវធនធានមនុស្សដែលមានគុណភាពនិងសមត្ថភាពខ្ពស់។ យុទ្ធសាស្ត្រចតុកោណជំណាក់កាលទី៣ ចាត់ទុកវិស័យអប់រំជាវិស័យគន្លឹះសម្រាប់ការឈានឡើងនៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងដំណាក់កាលថ្មី និងការឈានទៅសម្រេចឋានៈប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍឆ្នាំ២០៥០។ ដូច្នេះការផ្ទេរសាលាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក គឺជាកត្តាគន្លឹះដែលក្រសួងអប់រំ យុវជន និងកីឡា បាន និងកំពុងផ្ដោតយកចិត្តទុកដាក់ និងជាប្រធានបទដែលជំរុញ និងលើកទឹកចិត្តអ្នកស្រាវជ្រាវឱ្យមានការសិក្សាស្រាវជ្រាវ។

## ១.២ បញ្ហានៃការស្រាវជ្រាវ

ការអប់រំកុមារតូច សំដៅលើការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កុមារ ( ផ្នែកសង្គម ផ្លូវចិត្ត ផ្នែកចំណេះដឹង និងផ្នែកផ្លូវកាយ) ដើម្បីស្ថាបនាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការរៀនសូត្រពេញមួយជីវិត និងសុខុមាលភាព ដូចមានចែងក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ ការគាំពារនិងអប់រំកុមារតូច រួមមានការផ្ដោតការយកចិត្តទុកដាក់លើការដាក់បញ្ចូលភាពត្រៀមខ្លួនរួចជាស្រេចរបស់កុមារ សម្រាប់ការអប់រំថ្នាក់បឋមសិក្សា។

កុមារតូចមានការអភិវឌ្ឍឆាប់រហ័សផ្នែកខួរក្បាលនៅដំណាក់កាលដំបូងនៃជីវិត។ បទពិសោធជាច្រើនបានបង្ហាញថា ជីវិតដំបូងរបស់កុមារត្រូវផ្ដោតទៅលើការថែទាំ ការជួយទំនុកបម្រុងពីគ្រួសារ និងសង្គមឱ្យទទួលបាននូវសេវានានាដូចជា អាហារូបត្ថម្ភ ការថែទាំសុខភាព ការផ្ដល់ឱកាសរៀនសូត្រ និងការការពារពីគ្រោះថ្នាក់ផ្សេងៗ។ ការអប់រំ និងការអភិវឌ្ឍកុមារតូចសម្បូទាពេញលេញ គឺជាការកសាងមូលដ្ឋានគ្រឹះសម្រាប់ការរៀនសូត្រពេញមួយជីវិតទាំងសុខភាពផ្លូវកាយ និងផ្លូវចិត្ត ជាពិសេសបំណិនពុទ្ធិបញ្ញា និងបំណិនមិនមែនពុទ្ធិបញ្ញា ដើម្បីប្រែក្លាយជាមូលធនមនុស្សឆ្ពោះទៅកាន់សង្គមពុទ្ធិ សម្រាប់កសាងសង្គមមួយដែលមានការអភិវឌ្ឍប្រកបដោយសុខសន្តិភាព។

ការអប់រំកុមារតូច(SDGs, 2030) បានកំណត់នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាការប្ដេជ្ញាចិត្តកម្រិតសាកល គ្របដណ្ដប់លើគោលដៅពាក់ព័ន្ធជាមួយការអភិវឌ្ឍផ្សេងៗជាច្រើន។ បណ្ដាប្រទេសដែលបានចុះហត្ថលេខាលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព បានព្រមព្រៀង

ធ្វើផែនការ និងសម្រេចឱ្យបានតាមគោលដៅ ដែលបានព្រមព្រៀងក្នុងប្រទេសរៀងៗខ្លួនត្រឹមឆ្នាំ២០៣០។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រូវបានបំបែកទៅជាចំណុចដៅចំនួន ១៦៩ និងសូចនាករចំនួន ២៣០ ។

ការយកចិត្តទុកដាក់លើការគាំពារ ថែទាំ និងអប់រំកុមារតូច(រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៤៨ ឆ្នាំ១៩៩៣) គឺជាការធានារក្សាការពារសិទ្ធិរបស់រដ្ឋចំពោះកុមារ ដែលមានសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវទទួលបានការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណកុមារ។ ការអប់រំ និងការរៀនសូត្ររបស់កុមារគឺជាតម្រូវការរបស់កុមារក្នុងការទទួលបាននូវអន្តរាគមន៍ដល់សុខមាលភាព។ ការគាំពារ និងអប់រំកុមារតូច (ច្បាប់អប់រំ មាត្រា១៦, ២០១៧, ទំព័រ ៥) គឺជាកាតព្វកិច្ចរបស់រដ្ឋក្នុងការផ្តល់សេវាអប់រំដល់កុមារចាប់ពីកម្រិតសូន្យឆ្នាំមុនមត្តេយ្យសិក្សា ដែលជាទូទៅប្រព្រឹត្តនៅទារកដ្ឋាន នៅសហគមន៍ ឬនៅផ្ទះ។ ជាមួយគ្នានេះដែរ កុមារតូចទាំងអស់ចាប់តាំងពីកកំណើតរហូតដល់អាយុក្រោមប្រាំមួយឆ្នាំ ត្រូវទទួលបានសេវាគាំពារ និងអភិវឌ្ឍ ជាពិសេសកុមាររងគ្រោះ កុមារងាយរងគ្រោះ និងក្រខ្សត់ ដែលនេះត្រូវបានចាត់ទុកជា ចក្ខុវិស័យ ដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការគាំពាគោលនយោបាយជាតិ និងការយកចិត្តទុកដាក់អភិវឌ្ឍលើគ្រប់វិស័យ។ ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាគន្លឹះដែលរាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់។

វិស័យអប់រំនៅកម្ពុជាមានការរីកចម្រើនជាលំដាប់។ សន្តិភាព និងស្ថេរភាពសង្គម បានផ្តល់ឱកាសដល់ក្រសួងអប់រំ យុវជន និងកីឡាអនុវត្តគោលនយោបាយអប់រំ និងផ្តួចផ្តើមអនុវត្តកម្មវិធីនានា ជាពិសេសការបង្កើនល្បឿននៃកំណែទម្រង់វិស័យអប់រំ ជាបន្តបន្ទាប់។ ក្នុងអំឡុងពេលចុងក្រោយនេះ ការអប់រំនៅកម្ពុជា បានដំណើរការល្អប្រសើរ និងរីកចម្រើនគួរជាទីមោទនៈ។ ការពង្រីកសេវាអប់រំនៅគ្រប់កម្រិតបានធ្វើឱ្យលទ្ធភាពទទួលបានសេវាអប់រំកាន់តែកើនឡើងជាលំដាប់សម្រាប់សិស្សានុសិស្សបានរៀនសូត្រទៅតាមកម្មវិធីដែលក្រសួងបានកំណត់។ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំជាបន្តបន្ទាប់ និងអនុវត្តនូវកំណែទម្រង់អាទិភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពស្តីពីការអប់រំនៅឆ្នាំ២០៣០។ ការធ្វើបច្ចុប្បន្នភាពសេវាអប់រំកុមារតូច ទៅរដ្ឋបាលក្រុង/ស្រុកគឺជំរុញកិច្ចអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រតាមរយៈការចូលរួមធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងតម្រូវការចាំបាច់នានានៅមូលដ្ឋាន។

ក្នុងឆ្នាំ២០១៦ ខេត្តបាត់ដំបងគឺជាខេត្តមួយដែលក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ និងបានផ្ទេមុខងារជាដំណាក់

កាល ដែលក្នុងនោះមានចែងច្បាស់អំពីមុខងារកម្រិតគ្រប់គ្រងនៅ រដ្ឋបាលក្រុងស្រុក មានតួនាទីគ្រប់គ្រង ចាត់ចែង ដឹកនាំ និងធានានិរន្តរភាពនៃការអនុវត្តកម្មវិធីដែលបានផ្ទេរឱ្យ ខណៈពេលដែលមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើរតួជាអ្នកសម្របសម្រួល សហការលើការបំពេញការងារស្របតាមស្តង់ដា និងលិខិតបទដ្ឋាននានាដោយមានការកំណត់ និងការពិនិត្យតាមដាន។ ដោយផ្អែកលើការងារនេះ ក្រសួងអប់រំ យុវជន និងកីឡា ជាអ្នករៀបចំគោលនយោបាយ ច្បាប់ ស្តង់ដា (បុគ្គលិក កម្មវិធីសិក្សា និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ) ការអភិវឌ្ឍសមត្ថភាព (បណ្តុះបណ្តាលជ្រើសរើស) និងការត្រួតពិនិត្យគុណភាពសេវា។

បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃរដ្ឋបាលខេត្តបាត់ដំបងបានទទួលការអភិវឌ្ឍសមត្ថភាពដើម្បីត្រៀមទទួលយកការផ្ទេមុខងារការអប់រំកុមារតូច (ក្រសួងអយក, ២០១៦, ទំព័រ ១០៨) ដោយគណៈគ្រប់គ្រងសាលារៀនបានទទួលការបណ្តុះបណ្តាលអំពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលតាមសាលាមត្តេយ្យសិក្សា និងការគ្រប់គ្រងសាលាថ្នាក់មត្តេយ្យសិក្សាសហគមន៍ ។

ការសិក្សាស្រាវជ្រាវនេះ គឺមានគោលបំណងសិក្សា និងស្វែងយល់ពីការធ្វើបច្ចុប្បន្នភាពនៃការផ្ទេសេវាអប់រំកុមារតូច ទៅរដ្ឋបាលក្រុង/ស្រុក ដើម្បីជានា និងអភិវឌ្ឍគុណភាពអប់រំនៅថ្នាក់ក្រោមជាតិប្រកបដោយគុណភាព និងប្រសិទ្ធភាព។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងដូចខាងក្រោម៖

ទី១. សិក្សាពីការគ្រប់គ្រង និងការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក

ទី២. ស្វែងយល់ពីផលជះនៃការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក

## ១.៤ សំណួរនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវខាងលើ ការសិក្សានេះបានបង្កើតសំណួរស្រាវជ្រាវចំនួនពីររួមមាន៖

១. តើការគ្រប់គ្រង និងការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក មានស្ថានភាពបែបណា?

២. តើការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុកមានផលជះអ្វីខ្លះ ក្នុងការលើកកម្ពស់គុណភាពអប់រំនៅថ្នាក់ក្រោមជាតិ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានផ្តល់នូវសារៈសំខាន់ជាច្រើន រួមមានៈ ១) ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសេវាអប់រំកុមាតូចនៅថ្នាក់ក្រោមជាតិ និង ២)ការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកផ្តល់សេវាអប់រំ និងអ្នកទទួលសេវាអប់រំប្រកបដោយគុណភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំ។

## ១.៦ ដែនកំនត់នៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវមានដំណើរការទៅបានល្អ និងវិភាគបានគ្រប់ជ្រុងជ្រោយលើប្រធានបទ "**ស្ថានភាពនៃការធ្វើបច្ចុប្បន្នភាពសេវាអប់រំកុមារតូច ទៅរដ្ឋបាលក្រុង/ស្រុកក្នុងខេត្តបាត់ដំបង**» ការសិក្សានេះ ផ្តោតទៅលើកុមារមត្តេយ្យសិក្សាអាយុ៥ឆ្នាំ(ថ្នាក់កម្រិតខ្ពស់) នៅក្នុងឆ្នាំសិក្សា២០២១-២០២២។ ការសិក្សាស្រាវជ្រាវបានជ្រើសរើសយកសាលា មត្តេយ្យសិក្សាសាធារណៈ និងសាលាមត្តេយ្យសិក្សាសហគមន៍ស្ថិតនៅខេត្តបាត់ដំបង រួមមានៈសាលាមត្តេយ្យសិក្សារដ្ឋដាច់ដោយឡែកចំនួន២៦សាលា ថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សាចំនួន៣សាលា និងមត្តេយ្យសិក្សាសហគមន៍ស្តង់ដាចំនួន៣២ សាលា នៃក្រុង/ស្រុក ចំនួន១៤ (ក្រុងបាត់ដំបង ស្រុកសង្កែ ស្រុកមោងឫស្សី ស្រុកបាណន់ ស្រុកឯកភ្នំ ស្រុកថ្មគោល ស្រុកបវេល ស្រុករតនមណ្ឌល ស្រុកសំឡូត ស្រុកកំរៀង ស្រុកគាស់ក្រឡ ស្រុកភ្នំព្រឹក ស្រុកសំពៅលូន និងស្រុករុក្ខគិរី)ក្នុងខេត្តបាត់ដំបង។ ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់ឧបករណ៍សម្ភាសន៍សម្រាប់ការសម្ភាសន៍នាយក/នាយិកា គណៈគ្រប់គ្រងសាលា ថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងគ្រូមត្តេយ្យសិក្សា។ ការសិក្សាស្រាវជ្រាវនេះ បានជ្រើសរើសសំណាកចំនួន ៤២៨នាក់ (អ្នកគ្រប់គ្រងសេវាមាន ថ្នាក់ដឹកនាំមន្ទីរអេយកខេត្ត មន្ត្រីជំនាញអប់រំកុមារតូច,មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុងស្រុកទាំង១៤ ចំនួន១៦នាក់ នាយក/នាយិកាសាលាសាធារណៈចំនួន២៩នាក់(សាលាមត្តេយ្យសិក្សាដាច់ដោយឡែកចំនួន២៦នាក់ និងសាលាបឋមសិក្សាដែលមានថ្នាក់មត្តេយ្យសិក្សាចំនួន៣នាក់) គណៈគ្រប់គ្រងសាលា ថ្នាក់មត្តេយ្យសិក្សាសហគមន៍ចំនួន៣៦នាក់ គ្រូមត្តេយ្យសិក្សាសរុបមត្តេយ្យសិក្សាសាធារណៈ និងមត្តេយ្យសិក្សាសហគមន៍ចំនួន ១៥២នាក់) យោងតាមចំនួនសំណាកខាងលើ ការសិក្សាស្រាវជ្រាវនេះ គឺមានចំណុចខ្វះចន្លោះមួយចំនួនរួមមានៈ ចំនួនសំណាកមិនទាន់សមស្រប ការប្រើប្រាស់ឧបករណ៍ប្រមូលទិន្នន័យ(សម្ភាសន៍) និងការបកស្រាយទិន្នន័យមិនទាន់បានល្អក្បោះក្បាយ និងស៊ីជំរៅ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមាន ៥ជំពូក។ ជំពូក១ បង្ហាញពីសេចក្តីផ្តើម រួមមានៈលំនាំបញ្ហានៃការស្រាវជ្រាវ បញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។ ជំពូក២ រំលឹក និងពន្យល់បកស្រាយពីរំលឹកទ្រឹស្តី រួមមានៈ និយមន័យពាក្យគន្លឹះ សេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា កម្មវិធីសិក្សាអប់រំកុមារតូចនៅមត្តេយ្យសហគមន៍ និងការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា ជំពូក៣ បង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ រួមមាន៖ ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ(វិធីសាស្ត្រស្រាវជ្រាវ និងឧបករណ៍ស្រាវជ្រាវ) សំណាកគំរូ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីសាស្ត្រវិភាគទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។ ជំពូក៤ បកស្រាយពីលទ្ធផលសិក្សា និងពិភាក្សា រួមមាន៖ ការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង-ស្រុក ការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា និងផលជះក្នុងការលើកការលើកកម្ពស់គុណភាពអប់រំកុមារតូចនៅរដ្ឋបាលក្រុង/ស្រុក។ ចំពោះការពិភាក្សាលើលទ្ធផលស្រាវជ្រាវ មាន (១) យន្តការនៃការផ្ទេរសេវាអប់រំកុមារតូចនៅរដ្ឋបាលក្រុង-ស្រុក (២) យុទ្ធសាស្ត្រនៃការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា និង (៣) សារៈសំខាន់នៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។ ជំពូក៥ បង្ហាញពីសេចក្តីសន្និដ្ឋាន និងអនុសាសន៍។ ជំពូកនេះ គឺបកស្រាយពីប្រសិទ្ធភាពនៃការផ្ទេរសេវាអប់រំនៅមត្តេយ្យសិក្សា កំណែលម្អគុណភាពអប់រំនៅមត្តេយ្យសិក្សា និងសំណូមពរដល់អ្នកសិក្សាស្រាវជ្រាវបន្ត។

# ជំពូក ២

# រំលឹកទ្រឹស្តី

# ជំពូក ២

# រំលឹកទ្រឹស្តី

ជំពូកទី២ មានគោលបំណងពន្យល់បកស្រាយពីនិយមន័យនៃពាក្យគន្លឹះ «ការធ្វើបច្ចុប្បន្នភាពសេវាអប់រំ» និង«ការអប់រំកុមារតូច»។ ជំពូកនេះ បានបង្ហាញ និងពន្យល់បកស្រាយអំពីសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សារួមមានសេវាអប់រំកុមារតូចមត្តេយសិក្សាសាធារណៈ និងឯកជន និងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សាសហគមន៍។ ជំពូកនេះ ក៏បានពន្យល់បកស្រាយអំពីកម្មវិធីសិក្សាអប់រំកុមារតូចនៅមត្តេយ្យសិក្សា ដែលមានកម្មវិធីសិក្សាអប់រំកុមារតូចនៅមត្តេយ្យសិក្សាសាធារណៈ និងឯកជន និងកម្មវិធីសិក្សាអប់រំកុមារតូចនៅមត្តេយ្យសិក្សាសហគមន៍។ ជាចុងក្រោយ ជំពូកនេះបានបង្ហាញ និងពន្យល់បកស្រាយពីការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា រួមមានការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សាសាធារណៈ ឯកជន និងការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សាសហគមន៍។

## ២.១ និយមន័យនៃពាក្យគន្លឹះ

ការពន្យល់ពាក្យគន្លឹះ បានជួយឱ្យអ្នកស្រាវជ្រាវមានភាពងាយស្រួលក្នុងការបកស្រាយខ្លឹមសារនៃការសិក្សាស្រាវជ្រាវនេះប្រកបដោយភាពស៊ីជម្រៅ និងច្បាស់លាស់។ ការសិក្សាស្រាវជ្រាវនេះ បានពន្យល់ និងបកស្រាយនិយមន័យពាក្យគន្លឹះ «ការធ្វើបច្ចុប្បន្នភាពសេវាអប់រំ» និង«ការអប់រំកុមារតូច»។

### ២.១.១ ការធ្វើបច្ចុប្បន្នភាពសេវាអប់រំ

លោក ( David, 1995 ) បានលើកឡើងថា ការធ្វើបច្ចុប្បន្នភាពេវាអប់រំ គឺសំដៅដល់គោលគំនិតសំខាន់ដែលមានទំនាក់ទងជាមួយកម្មវិធីនយោបាយ, រដ្ឋបាលសាធារណៈសម្រាប់ដោះស្រាយ ការអភិវឌ្ឍស្តង់ដារ និងការទទួលស្គាល់នៅក្នុងប្រទេស ជាពិសេសភាគីពាក់ព័ន្ធសំខាន់ៗ (អ្នកផ្តល់សេវាអប់រំ)។ ការធ្វើបច្ចុប្បន្នភាពសេវាអប់រំ គឺជាតម្រូវការស្តង់ដារអប់រំរួមទាំងគ្រឹះស្ថានសិក្សាសាធារណៈ ឯកជន និងសមត្ថភាពក្នុងការរួមចំណែកយ៉ាងសកម្មក្នុងដំណើរការអភិវឌ្ឍ។ រដ្ឋបាលអប់រំរួមមាន ការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រង និងទំនាក់ទំនងរវាងស្ថាប័នបណ្តុះបណ្តាល (អ្នកផ្គត់ផ្គង់សេវាអប់រំ) និងស្ថាប័នកំណត់ស្តង់ដារ (អ្នកត្រួតត្រួតពិនិត្យការអភិវឌ្ឍស្តង់ដារ), ហិរញ្ញប្បទាននៃការអភិវឌ្ឍ និងប្រតិបត្តិការការងារបន្ត ហើយផ្សាភ្ជាប់ពីសេវាថ្នាក់ជាតិទៅនឹងថ្នាក់ក្រោមជាតិ, ការផ្សព្វផ្សាយ និងការធ្វើបច្ចុប្បន្នភាពស្តង់ដារជាតិ។ ការធ្វើបច្ចុប្បន្នភាពសេវាអប់រំ គឺជាការកែលម្អកម្មវិធីសិក្សា និងការផ្ទេរសេវាអប់រំនៅ

តាមគ្រឹះស្ថានសិក្សាដែលជាប្រយោជន៍ និងសំដៅលើទិដ្ឋភាពអប់រំរួមមាន វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា (ណារ៉ុន, ២០២១)។ ក្នុងការសិក្សាស្រាវជ្រាវនេះ ការធ្វើបច្ចុប្បន្នភាពសេវាអប់រំគឺសំដៅលើមធ្យោបាយ វិធីសាស្ត្រ និងសកម្មភាពដែលបម្រើដល់ការអប់រំដោយការបង្កើននូវចំណេះដឹងដល់អ្នកសិក្សារៀនសូត្រ និងការផ្ទេរសេវាអប់រំទៅគ្រឹះស្ថានសិក្សា ដែលជាថ្នាក់ក្រោមជាតិ(ការផ្ទេរសេវាអប់រំកុមារតូចទៅថ្នាក់ក្រោមជាតិ)។

## ២.១.២ អប់រំកុមារតូច

ការអប់រំកុមារតូច ជាសកម្មភាព ឬបទពិសោធន៍ដែលជះឥទ្ធិពលដល់ការផ្លាស់ប្តូរការអភិវឌ្ឍរបស់កុមារតូចមុនពេលពួកគេចូលរៀននៅសាលាបឋមសិក្សា។ ការអប់រំកុមារតូច មានន័យថាការអភិវឌ្ឍរបស់កុមារតូច ហើយវ័យរបស់កុមារតូចក្តោបលើរយៈពេលចាប់ពីសម្រាលរហូតដល់អាយុ៨ឆ្នាំ (ក្រសួងអយក, ២០១០, ទំព័រ ១០)។ យោងតាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡា (២០២០) ការអប់រំកុមារតូច គឺសំដៅការគាំពារ និងអភិវឌ្ឍកុមារចាប់ពីប្រសូតរហូតដល់អាយុក្រោម៦ឆ្នាំ (បរិបទក្នុងប្រទេសកម្ពុជា)។ ការអប់រំកុមារតូច គឺជាការអភិវឌ្ឍ និងការរៀនសូត្រក្នុងវ័យកុមារតូច។ C.A. Nelson, ( 2000 ) បានលើកឡើងថា កម្មវិធីអភិវឌ្ឍកុមារតូច ឬមត្តេយ្យសិក្សាបានផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍផ្នែកភាសា ចំណេះដឹង និងចិត្តសង្គម និងការត្រៀមខ្លួនសម្រាប់ការចូលរៀន។ យោងតាមទ្រឹស្តីរបស់ OECD, ( 2018 ) ការអភិវឌ្ឍកុមារតូច គឺជាការធ្វើឱ្យកុមារមានការរីកលូតលាស់ទាំងផ្នែករូបរាងកាយ បញ្ញា ស្មារតី ភាសា អារម្មណ៍ សង្គម ដែលជាវ័យដំបូងរបស់ពួកគេ ហើយវ័យនេះ គឺជាពេលដែលត្រូវការអភិវឌ្ឍ និងការរៀនសូត្របានល្អប្រសើរ និងចាំបាច់ត្រូវតែជំរុញឱ្យមានការអភិវឌ្ឍ និងការរៀនសូត្រក្នុងវ័យកុមារតូច។ ការសិក្សានេះបានបង្កើតទ្រឹស្តីថា ការអប់រំកុមារតូច គឺសំដៅលើការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កុមារ (ផ្នែកសង្គម ផ្លូវចិត្ត ផ្នែកចំណេះដឹង និងផ្នែកផ្លូវកាយ) ដើម្បីស្ថាបនាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការរៀនសូត្រពេញមួយជីវិត និងសុខុមាលភាពដែលមានចែងក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ ការគាំពារ និងការអប់រំកុមារតូចរួមមាន ការផ្តោតការយកចិត្តទុកដាក់លើការដាក់បញ្ចូលភាពត្រៀមខ្លួនរួចជាស្រេចរបស់កុមារសម្រាប់ការអប់រំថ្នាក់បឋមសិក្សា។ កុមារតូចមានការអភិវឌ្ឍឆាប់រហ័សផ្នែកខួរក្បាលនៅដំណាក់កាលដំបូងនៃជីវិត។ ការអប់រំ និងការអភិវឌ្ឍសម្បទាពេញលេញរបស់កុមារតូច គឺជាការកសាងមូលដ្ឋានគ្រឹះសម្រាប់ការរៀនសូត្រពេញមួយជីវិត ទាំងសុខភាពផ្លូវកាយ និងផ្លូវចិត្ត ជាពិសេសបំណិនពុទ្ធិបញ្ញា និងបំណិនមិនមែនពុទ្ធិបញ្ញា ដើម្បីប្រែក្លាយជាមូលធនមនុស្សឆ្ពោះទៅកាន់សង្គមពុទ្ធិសម្រាប់ការកសាងសង្គមដែលមានការអភិវឌ្ឍប្រកបដោយសុខសន្តិភាព។

## ២.២ ការផ្តល់សេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា

បន្ទាប់ពីការដួលរលំរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ការអប់រំនៅថ្នាក់មត្តេយ្យសិក្សា ត្រូវបានបង្កើតឡើងដោយក្រុមការងារបច្ចេកទេសអប់រំចំណេះទូទៅ និងមត្តេយ្យសិក្សាដែលបានក្លាយជានាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា (ក្រសួងអយក, ទំព័រ ៣៤)។ ក្នុងឆ្នាំ១៩៩៩ នាយកដ្ឋាននេះ បានចែកជាពីរ គឺនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងនាយកដ្ឋានបឋមសិក្សានិងមត្តេយ្យសិក្សា។ នាយកដ្ឋានអប់រំកុមារតូច (ECED) បានបង្កើតឡើងនៅឆ្នាំ ២០០២។ ការអប់រំកុមារតូច គឺត្រូវបានគាំទ្រទាំងស្រុងដោយរាជរដ្ឋាភិបាលកម្ពុជា និងត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់។ ការអប់រំនៅមត្តេយ្យសិក្សា គឺជាការអប់រំសម្រាប់កុមារអាយុ៣ឆ្នាំ ដល់៥ឆ្នាំ (នា.អកត, ២០១៨)។ ការអប់រំកុមារតូចបានបែងចែកជាបីកម្រិតៈ ថ្នាក់កម្រិតទាប សម្រាប់កុមារអាយុ៣ឆ្នាំ ថ្នាក់កម្រិតមធ្យម សម្រាប់កុមារអាយុ ៤ឆ្នាំ និងកម្រិតខ្ពស់ សម្រាប់កុមារអាយុ៥ឆ្នាំ។ សាលាមត្តេយ្យសិក្សាដាច់ដោយឡែក គឺសំដៅលើសាលាដែលមានថ្នាក់៣កម្រិត ហើយថ្នាក់មត្តេយ្យសិក្សាកម្រិតខ្ពស់ក៏មាននៅក្នុងសាលាបឋមសិក្សាផងដែរ។

ការអប់រំកុមារតូចរាប់បញ្ចូលទាំងមត្តេយ្យសិក្សាសហគមន៍ ដែលទទួលខុសត្រូវដោយក្រុមប្រឹក្សាឃុំ/សង្កាត់ និងកម្មវិធីអប់រំកុមារតូចតាមផ្ទះជាការរួមចំណែកស្ម័គ្រចិត្តរបស់ម្តាយបង្គោលនៅតាមភូមិ ដែលគ្មានមត្តេយ្យសិក្សាសាធារណៈ និងមត្តេយ្យសិក្សាសហគមន៍នៅក្បែរ។ មត្តេយ្យសិក្សាឯកជន គឺជាការចូលរួមវិនិយោគរបស់វិស័យឯកជន។ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងវិស័យអប់រំ សេវាអប់រំកុមារតូច ត្រូវបានធ្វើការផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងបង្ខិតសេវាអប់រំទៅកៀកជិតជាមួយពលរដ្ឋ និងបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានសេវាទាំងនេះរួមមានមត្តេយ្យសិក្សាសាធារណៈ មត្តេយ្យសិក្សាឯកជន មត្តេយ្យសិក្សាសហគមន៍ និងកម្មវិធីអប់រំមាតាបិតា ឬកម្មវិធីអប់រំកុមារតូចតាមផ្ទះ។

### ២.២.១ សេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សាសាធារណៈ និងឯកជន

មត្តេយ្យសិក្សាសាធារណៈ និងឯកជន គឺជាផ្នែកមួយនៃការផ្តល់សេវាអប់រំកុមារតូច ដែលកុមាររៀនតាមកម្រិតថ្នាក់ត្រូវជាមួយកម្រិតអាយុ។ ប្រទេសនៅអឺរ៉ុបភាគច្រើនរួមមាន ប្រទេសបែលហ្សិក, អ៊ីតាលី, ហូឡង់ និងចក្រភពអង់គ្លេស គឺបានគាំទ្រមូលនិធិសម្រាប់ការគាំទ្រការបង្រៀននិងរៀនដល់កុមារមុនចូលរៀននៅសាលាបឋមសិក្សា ដែលកុមារតូចមានសិទ្ធិស្របច្បាប់ក្នុងការចូលរៀនមិនគិតថ្លៃ លើកលែងតែប្រទេសដាណឺម៉ាក និងស៊ុយអែត ដែល

ឪពុកម្តាយធ្វើការបង់ថ្លៃទៅដល់អ្នកផ្តល់សេវាអប់រំ (Hasan, 2007a)។ អភិបាលកិច្ច ត្រូវតែប្រឈមនឹងចំណុចចំនួនប្រាំៈ(១) ប្រភេទនិងគុណភាពនៃសេវាអប់រំកុមារតូច (២) ខ្លឹមសារនិងគរុកោសល្យ ដែលត្រូវផ្តល់ជូន (៣) អ្នកណាគួរទទួលបានផលប្រយោជន៍ពីសេវាកម្ម (៤) អ្វីដែលគួរផ្តល់និងការវិនិយោគធនធាន និង(៥) អ្នកណាគួរបង់ការចំណាយរដ្ឋាភិបាល ផ្នែកឯកជន ឬឪពុកម្តាយ។ ការអនុវត្តសេវាអប់រំកុមារតូចគឺត្រូវតែបែងចែកការទទួលខុសត្រូវរួមគ្នារវាងវិស័យឯកជន និងរដ្ឋាភិបាលដើម្បីរួមចំណែកគាំទ្រ ឬរួមចំណែកទទួលខុសត្រូវអ្វីខ្លះដែលធ្វើឡើងដោយឪពុកម្តាយ (Hasan, 2007b)។

សារៈសំខាន់នៃការអប់រំមត្តេយ្យសិក្សា គឺជានិន្នាការមួយក្នុងចំណោមនិន្នាការទូទាំងពិភពលោក។ កុមារដែលចូលរៀននៅសាលាមត្តេយ្យសិក្សា គឺមានការរៀនសូត្រប្រសើរជាងក្នុងការទទួលបានចំណេះដឹង និងជំនាញសិក្សានៅគ្រប់កម្រិតនៃការអប់រំ ហើយមានទំនោរទៅកាន់ភាពជោគជ័យក្នុងជីវិត គិតត្រឹមថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១០ ចំនួនកុមារចូលរៀនសេវាមត្តេយ្យសិក្សានៅកាហ្សាក់ស្ថាន បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០០៥ កើនឡើង ១៦,៨ ភាគរយ។ ក្នុងតំបន់ទីក្រុង កុមារ១នាក់ក្នុងចំណោម៣នាក់ បានចូលរៀននៅមត្តេយ្យសិក្សា និងនៅតាមតំបន់ជនបទ កុមារ៥នាក់ ក្នុងចំណោម១០០នាក់ បានចូលរៀននៅមត្តេយ្យសិក្សា (Duisembekova, 2013)។

មត្តេយ្យសិក្សាសាធារណៈ គឺសំដៅដល់ការអប់រំនៅមត្តេយ្យសិក្សា ដែលគ្រប់គ្រងដោយអាជ្ញាធរអប់រំសាធារណៈ ឬដោយភ្នាក់ងាររដ្ឋ ឬដោយក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាសាលារៀនដែលមានសមាជិកភាគច្រើនត្រូវបានតែងតែងដោយអាជ្ញាធរសាធារណៈ ឬត្រូវបានបោះឆ្នោតជ្រើសរើស។ មត្តេយ្យសិក្សាសាធារណៈ មានពីរប្រភេទគឺ មត្តេយ្យសិក្សាដាច់ដោយឡែក និងមត្តេយ្យសិក្សាស្ថិតក្នុងសាលាបឋមបឋមសិក្សា។ ជាទូទៅមត្តេយ្យសិក្សា គឺត្រូវបានចែកជាមត្តេយ្យសិក្សាកម្រិតទាប កម្រិតមធ្យម និងកម្រិតខ្ពស់ សម្រាប់ទទួលកុមារអាយុពី៣ ទៅដល់៧០ (ចិតសិប)ខែយ៉ាងតិច។ គ្រូមត្តេយ្យសិក្សាសាធារណៈ គឺជាបុគ្គលិកអប់រំ ដែលបានទទួលការបណ្តុះបណ្តាលរយៈពេល២ឆ្នាំនៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមនៅរាជធានីភ្នំពេញ (នា.បបវ, ២០១៣)។ មត្តេយ្យសិក្សាសាធារណៈ គឺមានកញ្ចប់ថវិកាមូលនិធិសម្រាប់ដំណើរការសាលារៀនសាធារណៈពីរដ្ឋាភិបាល និងថវិកាកែលម្អសាលារៀនរបស់ដៃគូអភិវឌ្ឍ។ មត្តេយ្យសិក្សាសាធារណៈ បានដំណើរការបង្រៀន និងរៀនដោយការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សាសាធារណៈ ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា។ សាលាមត្តេយ្យសិក្សាសាធារណៈដែលជាកន្លែងដំបូង បានដើរតួនាទីសំខាន់បំផុតនៅក្នុងការអភិវឌ្ឍការសិក្សារបស់កុមារអាយុពី៣ឆ្នាំ ទៅក្រោម៦ឆ្នាំ។ សាលាមត្តេយ្យសិក្សាសាធារណៈ គឺជាទីកន្លែងមួយដែលបានផ្តល់ការអប់រំដល់កុមារក្នុង

ការអភិវឌ្ឍចំណេះដឹង និងជំនាញក្នុងការត្រៀមចំណេះដឹងសម្រាប់ការសិក្សារៀនសូត្រនៅសាលាបឋមសិក្សា។ ក្នុងកំឡុងពេលសិក្សានៅសាលាមត្តេយ្យសិក្សា កុមារមានការអភិវឌ្ឍ និងការរីកលូតលាស់ទាំងផ្នែករូបរាងកាយ បញ្ញាស្មារតី ភាសា អារម្មណ៍ និងសង្គមនៅក្នុងវ័យដំបូងរបស់ពួកគេ។

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គឺមានតួនាទីផ្តល់សេវាអប់រំកម្រិតមត្តេយ្យសិក្សា និងមានភារកិច្ច (១) រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍគ្រឹះស្ថានសិក្សា និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់គ្រឹះស្ថានសិក្សា (២) គ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំមត្តេយ្យសិក្សា (៣) គ្រប់គ្រងសំណង់ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលាមត្តេយ្យសិក្សា (៤) គ្រប់គ្រងសំណង់អគារ សាងសង់ និងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងគ្រឹះស្ថានសិក្សា (៥) គ្រប់គ្រងសិស្សមត្តេយ្យសិក្សា (៦) គ្រប់គ្រងកម្មវិធីគាំទ្រការអប់រំកុមារតូច (៧) អភិវឌ្ឍវិស័យអប់រំដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា និង(៨) បំពេញការងារផ្សេងៗតាមការប្រគល់ការកិច្ចពីអភិបាលក្រុងស្រុក (រាជរដ្ឋាភិបាលកម្ពុជា, ២០១៩)។ ផ្អែកតាមតួនាទីនេះ ដំណើរការអភិវឌ្ឍសាលាមត្តេយ្យសិក្សា គឺជាសមាសភាពសំខាន់ដែលអ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សា គ្រូបង្រៀន និងបុគ្គលិកអប់រំ ចាំបាច់ត្រូវមានសមត្ថភាព ចំណេះដឹង ជំនាញ សីលធម៌ និងសមត្ថភាពវិជ្ជាជីវៈតាមគន្លងមួយជាក់លាក់។ អ្នកគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា គឺជាបុគ្គលិកអប់រំដែលបានអភិវឌ្ឍខ្លួនតាមគន្លងគណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា ក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណផលសិក្សារបស់សិស្សតាមរយៈការគ្រប់គ្រងលើការអនុវត្តកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ អាជ្ញាធរ និងសហគមន៍ គឺបានដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងតាមដានការរៀនសូត្ររបស់សិស្សានុសិស្ស និងជាសមាសភាពទ្រទ្រង់ការអភិវឌ្ឍគ្រឹះស្ថានដោយការលើកទឹកចិត្ត និងគាំទ្រក្នុងដំណើរការផ្តល់សេវាអប់រំដល់កុមារប្រកបដោយនិរន្តរភាព។ ការបង្កើត និងជំរុញការចូលរៀនរបស់សិស្សក្នុងសហគមន៍ ជាភ្នាក់ងាររក្សានូវសុវត្ថិភាព សន្តិភាពនិងផ្តល់ទំនុកចិត្តក្នុងដំណើរការអប់រំកុមារតូច ដែលជាយន្តការគន្លឹះក្នុងការផ្តល់ស្វ័យភាព និងភាពម្ចាស់ការកម្រឹតគ្រឹះស្ថានសិក្សាមត្តេយ្យសិក្សា។ មត្តេយ្យសិក្សាឯកជន គឺជាកម្មវិធីមត្តេយ្យសិក្សាដែលដំណើរការគ្រប់គ្រងដោយបុគ្គលឯកជន ឬដោយក្រុមប្រឹក្សាភិបាលឯកជន ឬក្រុមប្រឹក្សាសាលារៀនឯកជន សមាគមន៍ ឬអង្គការក្រៅរដ្ឋាភិបាល។ នៅឆ្នាំសិក្សា ២០២១-២០២២ កុមារអាយុ៣ឆ្នាំ បានទទួលសេវាអប់រំ ២,០១ភាគរយ ស្រី ២,០៣ភាគរយ អាយុ ៤ឆ្នាំ ទទួលសេវាអប់រំ ២,៩១ភាគរយ ស្រី ២,៩៩ភាគរយនិងអាយុ៥ឆ្នាំទទួលសេវាអប់រំ ៧,៦៨ភាគរយ ស្រី ៦,៥០ភាគរយ (ក្រសួងអយក, ២០២២a)។

## ២.២.២ សេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សាសហគមន៍

មត្តេយ្យសិក្សាសហគមន៍ គឺសំដៅដល់មណ្ឌល ឬថ្នាក់មត្តេយ្យសិក្សានៅតាមឃុំ/សង្កាត់ ដែលបង្កើតឡើងដោយរដ្ឋបាលឃុំ/សង្កាត់ ដោយការប្រើប្រាស់នូវមូលនិធិរបស់ឃុំ/សង្កាត់ ឬទទួលបានពីដៃគូអភិវឌ្ឍន៍ ឬសប្បុរសជន និងមានការគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងដៃគូអភិវឌ្ឍផ្សេងៗ។ គោលបំណងនៃការបង្កើតមត្តេយ្យសិក្សាសហគមន៍ គឺ(១)បង្កើនការចូលរៀនរបស់កុមារអាយុពី៣ឆ្នាំ ទៅក្រោម៦ឆ្នាំ (២)ពង្រីកការផ្តល់សេវាគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅឃុំសង្កាត់ (៣)រួមចំណែកបង្កើនអត្រាចូលរៀនរបស់កុមារអាយុ៦ឆ្នាំនៅសាលាបឋមសិក្សា និង(៤)កាត់បន្ថយអត្រាត្រួតថ្នាក់ និងការបោះបង់ការសិក្សានៅសាលាបឋមសិក្សា។ ការបង្កើតមត្តេយ្យសិក្សាសហគមន៍ មានគោលបំណងផ្តល់ឱកាសដល់កុមារ ដើម្បីអភិវឌ្ឍសមត្ថភាពពេញលេញលើផ្នែកទាំង៥ រួមមានផ្នែករាងកាយនិងសុខភាព វប្បធម៌និងសីលធម៌ សង្គមនិងអារម្មណ៍ ការយល់ដឹងនិងពិចារណា និងការអភិវឌ្ឍផ្នែកភាសា។ មួយវិញទៀត មត្តេយ្យសិក្សាហគមន៍បានផ្តល់ឱកាសដល់កុមារគ្រប់រូបជាពិសេសកុមារដែលងាយរងគ្រោះ កុមារជួបការលំបាក កុមារ ពិការ និងកុមារជនជាតិដើមភាគតិចទទួលបានសេវាអប់រំប្រកបដោយសមធម៌ (នា.អកត, ២០១៦a)។ មត្តេយ្យសិក្សាសហគមន៍ បានជួយបង្កើនការយល់ដឹងរបស់មាតាបិតា អាណាព្យាបាលនិងអាជ្ញាធរដែនដី លើដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារតូច ការថែទាំគាំពារកូន ការផ្តល់អាហារូបត្ថម្ភនិងការប្រើប្រាស់សេវាសុខាភិបាល គ្រួសារ និងសហគមន៍ (នា.អកត, ២០១៦b)។

មត្តេយ្យសិក្សាសហគមន៍ គឺបានផ្តល់អាទិភាពលើការផ្តល់សេវាអប់រំកុមារតូចក្នុងសហគមន៍។ មត្តេយ្យសិក្សាសហគមន៍ បានផ្តល់សេវាអប់រំកុមារតូចដោយការផ្តោតជាសំខាន់កុមារអាយុពី ៥(ប្រាំ)ឆ្នាំ ឬ៧០(ចិតសិប)ខែ។ ដើម្បីឱ្យស្របតាមនិន្នាការអប់រំបច្ចុប្បន្ន និងឱ្យដំណើរការការងារមត្តេយ្យសិក្សាសហគមន៍ ប្រកបដោយភាពរលូន និងនិរន្តរភាព ភូមិ/ឃុំសង្កាត់ណាដែលបង្កើតមត្តេយ្យសិក្សាសហគមន៍ គឺត្រូវបង្កើតកម្មវិធីអប់រំមាតាបិតា ជាពិសេសសម្រាប់មាតាបិតា ឬអាណាព្យាបាល ដែលមានកូនរៀននៅថ្នាក់មត្តេយ្យសិក្សាសហគមន៍ បានយល់ដឹងពីដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារតូច (ក្រសួងអយក, ២០២០)។

មត្តេយ្យសិក្សាសហគមន៍ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាអប់រំកុមារតូចប្រកបដោយភាពទូលំទូលាយ អនុវត្តសិទ្ធិកុមារ និងផ្តល់ឱកាសដល់កុមារគ្រប់រូប ជាពិសេសកុមារជួបការលំបាក កុមារពិការ និងកុមារជនជាតិដើមភាគតិច ដើម្បីទទួលបានសេវាអប់រំទូលំទូលាយ រួមចំណែកក្នុងការសម្រេចឱ្យបាននូវគោលដៅអប់រំ

សម្រាប់ទាំងអស់គ្នា និងពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងការផ្តល់និងគ្រប់គ្រងសេវាអប់រំនៅក្នុងសង្គមពិសេសមត្តេយ្យសិក្សាសហគមន៍ (នា.អកត, ២០១៤a)។ សារៈសំខាន់នៃមត្តេយ្យសិក្សាសហគមន៍ គឺបានផ្តល់សេវាអប់រំទៅមត្តេយ្យសិក្សាសហគមន៍ ជួយកុមារឱ្យមានមូលដ្ឋានគ្រឹះរឹងមាំក្នុងការត្រៀមខ្លួនចូលរៀននៅសាលាបឋមសិក្សា និងសិក្សាបន្តនៅគ្រប់ភូមិសិក្សាប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ (នា.អកត, ២០១៤b)។ មត្តេយ្យសិក្សាសហគមន៍ គឺផ្តល់នូវកម្មវិធីសិក្សាដែលឱ្យកុមារនូវជំនាញសង្គម និងការយល់ដឹង ផ្តោតទៅលើការសម្គាល់អក្សរលេខ អនាម័យផ្ទាល់ខ្លួន និងការធ្វើលំហាត់ប្រាណ និងអាកប្បកិរិយា សីលធម៌។ វិធីសាស្ត្រដែលប្រើដើម្បីបង្រៀនជំនាញពាក់ព័ន្ធ រួមមាន ការនិទានរឿង ការរៀនដឹកនាំដោយគ្រូតាមរយៈការប្រើប្រាស់បណ្ណរូបភាព និងសកម្មភាពសិក្សា ដូចជាការគូររូបលើខ្សាច់ ការច្រៀងចម្រៀង និងការស្វែងយល់ពីលក្ខណៈសម្បត្តិរបស់វត្ថុផ្សេងៗ (ក្រសួងអយក, ២០២១a)។ នៅក្នុងភូមិមួយ គ្រូបង្រៀនមត្តេយ្យសិក្សាសហគមន៍ធ្លាប់ជា «អ្នកមើលថែទាំកុមារ» ក្រោមកម្មវិធីដែលពាក់ព័ន្ធការងារអប់រំកុមារតូចពីមុន (Nirmala Rao, 2007)។ នៅឆ្នាំសិក្សា២០២១-២០២២ កុមារអាយុ៣ឆ្នាំ ទទួលសេវាអប់រំ ៥,២៤ភាគរយ ស្រី ៥,៦៣ភាគរយអាយុ៤ឆ្នាំ ទទួលសេវាអប់រំ ៧,៨៨ភាគរយ ស្រី ៨,៤៨ភាគរយនិងអាយុ៥ឆ្នាំ ទទួលសេវាអប់រំ ៨,៥១ភាគរយ ស្រី ៨,៨៤ភាគរយ (ក្រសួងអយក, ២០២២b)។

## ២.៣ កម្មវិធីសិក្សាការអប់រំកុមារតូចនៅមត្តេយ្យសិក្សា

កម្មវិធីសិក្សានៅកម្រិតការអប់រំកុមារតូច គឺការអភិវឌ្ឍចំណេះដឹងកុមារ ដើម្បីផ្តល់លទ្ធភាពឱ្យកុមារទទួលបានពេញលេញនូវសុខុមាលភាពរាងកាយ ផ្លូវចិត្ត ស្មារតី សាមគ្គីភាព និងភាពម្ចាស់ការ ការទទួលខុសត្រូវសមត្ថភាពពិចារណា ការដោះស្រាយបញ្ហា បំណិនអន្តរកម្មនិងសង្គម ស្មារតីស្រលាញ់បរិស្ថាន និងការចូលរួមរបស់កុមារ។ កម្មវិធីសិក្សានៅមត្តេយ្យសិក្សា មានគោលបំណងផ្តល់ឱ្យសិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា (ក្រសួងអយក, ឆ្នាំ២០១៦a)។ មុខវិជ្ជាសិក្សាដែលបានកំណត់ឱ្យសិក្សានៅមត្តេយ្យសិក្សា មាន៥មុខវិជ្ជា រួមមាន(១)មុខវិជ្ជាចិត្តចលភាព (២)មុខវិជ្ជាបុរេគណិត (៣)មុខវិជ្ជាភាសាខ្មែរ (៤)មុខវិជ្ជាវិទ្យាសាស្ត្រ (ទស្សនា សង្កេត ពិសោធន៍) និង (៥) សិក្សាសង្គម(ចម្រៀង គំនូរ សកម្មភាពកសាង សកម្មភាពប្រចាំថ្ងៃ ល្បែង និងអនាម័យនៅផ្ទះ)។ កម្មវិធីសិក្សាត្រូវកំណត់ឱ្យបង្រៀនចំនួន៣៥សប្តាហ៍ក្នុងមួយឆ្នាំសិក្សា ដែលត្រូវជា៥ថ្ងៃក្នុង១សប្តាហ៍ទៅតាមថ្នាក់កម្រិតទាប កម្រិតមធ្យម និងកម្រិតខ្ពស់ និង៦ម៉ោងសិក្សាក្នុង១ថ្ងៃ ដែល១ម៉ោងសិក្សា មានរយៈពេល៣០នាទី (ក្រសួងអយក, ២០១៦b)។ កម្មវិធី

សិក្សាសម្រាប់មត្តេយ្យសិក្សាមត្តេយ្យសិក្សាសាធារណៈ និងឯកជន អនុវត្តជាមួយគ្នា និងមត្តេយ្យសិក្សាសហគមន៍ អនុវត្តកម្មវិធីសិក្សាមួយផ្សេងទៀត។

## ២.៣.១ កម្មវិធីសិក្សាមត្តេយ្យសិក្សាសាធារណៈ និងឯកជន

កម្មវិធីសិក្សាមត្តេយ្យសិក្សាសាធារណៈ គឺត្រូវបានបែងចែកតាមកម្រិតថ្នាក់សិក្សា រួមមាន ថ្នាក់កម្រិតទាបសម្រាប់កុមារអាយុ៣ឆ្នាំ ថ្នាក់កម្រិតមធ្យមសម្រាប់កុមារអាយុ៤ឆ្នាំ និងថ្នាក់កម្រិតខ្ពស់សម្រាប់កុមារអាយុ៥ឆ្នាំ។ តាមកម្រិតថ្នាក់នៃមុខវិជ្ជានីមួយៗ មានប្រធានបទ ខ្លឹមសារ លទ្ធផលរំពឹងទុក និងចំនួនម៉ោង ដែលគ្រូបង្រៀនអាចយកទៅរៀបចំផែនការបង្រៀនប្រចាំថ្ងៃ និងរៀបចំកិច្ចតែងការសម្រាប់បង្រៀនកុមារ។ កម្មវិធីសិក្សានេះ គឺបានបំផុសគំនិតច្នៃប្រឌិត ការប្រើប្រាស់សម្ភារឧបទេស សម្ភាររូបវន្ត ប្រើប្រាស់ពេលវេលាសិក្សា និងការណែនាំក្នុងការបង្រៀននិងរៀន ដើម្បីធ្វើឱ្យសម្រេចគោលដៅសិក្សាស្របតាមអាយុកុមារ និងយន្តការនានាដើម្បីពង្រឹងប្រសិទ្ធភាពការងារក៏ជាគោលដៅសំខាន់សម្រាប់មត្តេយ្យសិក្សាផងដែរ (ក្រសួងអយក, ២០១៨a)។ គោលការណ៍គ្រឹះសម្រាប់អនុវត្តកម្មវិធីសិក្សារួមមាន (១)ការរៀន និងបង្រៀនត្រូវអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល (២)ការសិក្សារបស់កុមារត្រូវធ្វើឡើងតាមការលេង និងសហការ (៣)កុមារត្រូវបានផ្តល់ទំនុកចិត្ត ការលើកទឹកចិត្ត និងការទទួលខុសត្រូវក្នុងការរៀនសូត្រប្រកបដោយសុវត្ថិភាព និងភាពកក់ក្តៅ (៤)អន្តរកម្មនៃការសិក្សាប្រកបដោយគុណភាព កុមារនឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបទថ្មីៗបន្ថែមទៀតពីបរិស្ថានសិក្សារបស់ខ្លួន (៥)កុមារជាអ្នកកសាងសមត្ថភាពដោយខ្លួនឯង គ្រូជាអ្នកណែនាំ និងសម្របសម្រួល ដើម្បីឱ្យកុមាររៀនសូត្របានល្អប្រសើរ (៦)ការរៀបចំកិច្ចតែងការបង្រៀន ត្រូវធ្វើតាមគោលវិធីចម្រុះ (៧)បង្កើតយន្តការតាមដានការរៀនសូត្ររបស់កុមារប្រកបដោយប្រសិទ្ធភាព (៨)ការបង្រៀន និងរៀនត្រូវដំណើរការស្របតាមអាយុ វប្បធម៌ និងសមធម៌ (៩)ការរៀន និងការបង្រៀនត្រូវមានលក្ខណៈជាក់ស្តែង និងវិទ្យាសាស្ត្រ និង(១០)សាលារៀន និងគ្រូបង្រៀនត្រូវធ្វើអន្តរកម្មជាមួយអាណាព្យាបាល សហគមន៍ និងរដ្ឋអំណាច ដើម្បីធានាគុណភាព និងប្រសិទ្ធភាព (ក្រសួងអយក, ២០១៨b)។ ដើម្បីអនុវត្តកម្មវិធីសិក្សានេះប្រកបដោយគុណភាព និងប្រសិទ្ធភាព អ្នកអនុវត្តគ្រប់លំដាប់ថ្នាក់ ត្រូវរៀបចំធនធាន និងយន្តការមួយចំនួនដូចជា(១)អភិវឌ្ឍសៀវភៅណែនាំការបង្រៀនសម្រាប់គ្រូតាមមុខវិជ្ជាស្របតាមកម្រិតនៃក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ (២)អភិវឌ្ឍសម្ភារៈបម្រើឱ្យការបង្រៀននិងរៀន ឯកសារណែនាំប្រើប្រាស់សាមញ្ញ និងងាយស្រួលក្នុងការ អនុវត្ត (៣)អភិវឌ្ឍឯកសារជំនួយ និងអំណានបន្ថែមដទៃទៀត(ល្បែងសិក្សា ពាក្យបណ្តៅ

រឿងរូបភាព រឿងនិទានងាយៗ) ដើម្បីពង្រីកការរៀន និងបង្រៀន (៤)គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈនិងឯកជនត្រូវរៀបចំជាបន្ទប់ ឬជ្រុងថ្នាក់រៀនសម្រាប់លេង អានសៀវភៅ សម្តែង តន្ត្រី ទុកដាក់សម្ភារៈ និទានរឿង(៥) គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ ត្រូវរៀបចំទីធ្លាប្រកបដោយបរិស្ថានល្អ មានសុវត្ថិភាព សម្រាប់ដំណើរការលេងកម្សាន្ត ល្បែង និងហាត់ប្រាណជាដើម (៦) គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈនីមួយៗ ត្រូវរៀបចំផែនការបង្រៀនប្រចាំឆ្នាំ ប្រចាំខែ និងប្រចាំថ្ងៃ ស្របតាមពេលវេលា និងកម្មវិធីសិក្សាដែលបានកំណត់ ទី(៧)គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈនីមួយៗ ត្រូវរៀបចំយន្តការ និងឯកសារផ្សេងៗ ដើម្បីធ្វើអន្តរកម្មមានប្រសិទ្ធភាពរវាងសាលារៀន មាតាបិតា ឬអ្នកអាណាព្យាបាល និងសហគមន៍ (៨)គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនតាមម៉ោងពេលកំណត់ស្របតាមខ្លឹមសារកម្មវិធីសិក្សា និងសៀវភៅណែនាំគ្រូ (៩)រៀបចំធនធាននិងយន្តការថ្មីៗផ្សេងទៀត ដើម្បីពង្រឹងការអនុវត្តការអប់រំកុមារមត្តេយ្យសិក្សានៅកម្ពុជាប្រកបដោយការទទួលខុសត្រូវ (ក្រសួងអយក, ២០១៨c)។

មត្តេយ្យសិក្សាឯកជន មានពីរប្រភេទ គឺ(១) មត្តេយ្យសិក្សាជាតិ ដែលអនុវត្តតាមកម្មវិធីសិក្សាជាតិ រួមមានភាសាខ្មែរជាមុខវិជ្ជាគោលនៃកម្មវិធីសិក្សារបស់ខ្លួន (២) មត្តេយ្យសិក្សាអន្តរជាតិ ដែលអនុវត្តតាមកម្មវិធីសិក្សាអន្តរជាតិ និងត្រូវមានកម្មវិធីសិក្សាភាសាបរទេសណាមួយជាមុខវិជ្ជាគោលនៃកម្មវិធីសិក្សារបស់ខ្លួន។ មត្តេយ្យសិក្សាឯកជន ត្រូវដំណើរការបង្រៀន និងរៀន និងអនុវត្តតាមកម្មវិធីសិក្សា អាស្រ័យលើគ្រឹះស្ថាននីមួយៗ ដែលបានកំណត់ និងជ្រើសរើសគ្រូបង្រៀនដោយខ្លួនឯង (ក្រសួងអយក, ២០២១c)។

## ២.៣.២ កម្មវិធីសិក្សាមត្តេយ្យសិក្សាសហគមន៍

កម្មវិធីសិក្សាមត្តេយ្យសិក្សាសហគមន៍ គឺអភិវឌ្ឍកុមារផ្នែកកាយសម្បទា បំណិនសម្បទា និងចរិយាសម្បទា និងចំណេះដឹង និងជំនាញ ដែលជាចំណុចចាប់ផ្តើមនៃការទទួលយករបស់កុមារមុននឹងមានការប្រែប្រួលផ្នែកកាយសម្បទា និងចរិយាសម្បទា (ក្រសួងអយក, ២០២១b)។ បំណិនជាច្រើនរបស់កុមារ ដូចជា បំណិនដោះស្រាយបញ្ហា អន្តរកម្មបុគ្គលទំនាក់ទំនង និងបរិស្ថានជាដើម គឺត្រូវបានដាក់បញ្ចូលសមស្របតាមការអភិវឌ្ឍរូបរាងកាយ អាយុ និងវប្បធម៌របស់កុមារ (Bronfenbrenner, 2006) ។ កម្មវិធីសិក្សានេះបានបំផុសគំនិតច្នៃប្រឌិត ការប្រើប្រាស់សម្ភារៈឧបទេស សម្ភាររូបវន្ត ប្រើប្រាស់ពេលវេលាសិក្សា និងការណែនាំក្នុងការរៀន និងបង្រៀន ដើម្បីធ្វើឱ្យសម្រេចគោលដៅសិក្សាប្រកបដោយគុណភាព។ គ្រូបង្រៀន គឺដើរតួនាទីយ៉ាងសំខាន់ក្នុងសកម្មភាពរៀននិងបង្រៀន ដោយសម្របសម្រួលលើកទឹកចិត្តប្រើប្រាស់សម្ភារៈសមស្រប ជំរុញការរៀនសូត្ររបស់កុមារឱ្យមានភាពរស់រវើក និងសម្រេចគោលដៅ

សិក្សាស្របតាមអាយុរបស់កុមារ (Malaguzzi, 1994)។ គោលការណ៍គ្រឹះដើម្បីអនុវត្តកម្មវិធីសិក្សាមត្តេយ្យសិក្សាសហគមន៍នេះ មាន១០ចំណុច ដូចនឹងកម្មវិធីសិក្សាមត្តេយ្យសិក្សាសាធារណៈដែរ រួមមាន(១)ការរៀននិងបង្រៀនត្រូវអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌលនិងគោលវិធីចម្រុះ (២)ការសិក្សារបស់កុមារត្រូវធ្វើឡើងតាមការលេងនិងសហការ (៣)កុមារត្រូវបានផ្តល់ទំនុកចិត្ត និងការទទួលខុសត្រូវក្នុងការរៀនសូត្រប្រកបដោយសុវត្ថិភាព និងភាពកក់ក្តៅ (៤)អន្តរកម្មនៃការសិក្សាប្រកបដោយគុណភាព កុមារនឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបទថ្មីៗបន្ថែមទៀតពីបរិស្ថានរបស់ខ្លួន (៥)កុមារជាអ្នកកសាងសមត្ថភាពដោយខ្លួនឯង គ្រូជាអ្នកណែនាំ និងសម្របសម្រួល ដើម្បីឱ្យកុមាររៀនសូត្របានល្អប្រសើរ (៦)ការរៀបចំកិច្ចតែងការបង្រៀន ត្រូវធ្វើតាមវិធីចម្រុះ (៧)បង្កើតយន្តការតាមដានការរៀនសូត្ររបស់កុមារប្រកបដោយប្រសិទ្ធភាព (៨)ការបង្រៀននិងរៀនត្រូវដំណើរការស្របតាមអាយុ វប្បធម៌សិងសមធម៌ (៩)ការរៀននិងបង្រៀនត្រូវមានលក្ខណៈជាក់ស្តែង និងវិទ្យាសាស្ត្រ (១០)ថ្នាក់រៀននិងគ្រូបង្រៀនត្រូវធ្វើអន្តរកម្មជាមួយអាណាព្យាបាល សហគមន៍ ដើម្បីធានាគុណភាព និងប្រសិទ្ធភាព។ ការអនុវត្តកម្មវិធីសិក្សាសហគមន៍ រៀបចំធ្វើឡើងដូចកម្មវិធីសិក្សាសធារណៈផងដែរ (ក្រសួងអយក, ២០២១b)។

## ២.៤ ការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ និងអនុវិស័យការអប់រំកុមារតូច មានវត្ថុបំណងគោលនយោបាយចំនួន៣ គឺ(១)បង្កើនលទ្ធភាពការទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន(មាន៥យុទ្ធសាស្ត្រ) (២) បន្តអភិវឌ្ឍសាលាមត្តេយ្យសិក្សាស្របតាមស្តង់ដាគុណភាព (មាន៣យុទ្ធសាស្ត្រ) និង(៣)ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យការអប់រំកុមារតូច និងអនុវត្តការគ្រប់គ្រងតាមសាលារៀន (មាន២យុទ្ធសាស្ត្រ) និងបន្ថែមជាមួយសូចនាករផលសម្រេចចំនួន១៦សូចនាករ (ក្រសួងអយក, ២០១៩)។

ការអប់រំកុមារតូច គឺផ្តោតលើការអភិវឌ្ឍកុមារតូចផ្នែកទាំង៥ រួមមាន សុខភាពរាងកាយ ភាសា បញ្ញា និងការគិត សង្គម និងអារម្មណ៍ និងការអភិវឌ្ឍសីលធម៌និងវប្បធម៌ដោយផ្អែកលើមុខវិជ្ជាទាំង៥ ដែលមានមុខវិជ្ជា ចិត្តចលភាព មុខវិជ្ជាវិទ្យាសាស្ត្រ មុខវិជ្ជាសិក្សាសង្គម មុខវិជ្ជាបុរេគណិត និងមុខវិជ្ជាភាសាខ្មែរ ក្នុងគោលបំណងរួមចំណែកសម្រេចបានចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ (ក្រសួងអយក, ២០២១c)។ ដូចនេះ ការគ្រប់គ្រងសេវាអប់រំកុមារតូច គឺត្រូវមានយន្តការគ្រប់គ្រង វាយតម្លៃនិងពិនិត្យតាមដានការបង្រៀន និងរៀន មានដូចជា (១) ក្រសួងអប់រំ យុវជន និងកីឡា ចុះពិនិត្យតាមដានដំណើរការអនុវត្តការបង្រៀននិងរៀន និងសេវាអប់រំកុមារតូច របស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត (២) មន្ទីរអប់រំ យុវជន និងកីឡា ចុះពិនិត្យតាមដានដំណើរ

ការបង្រៀននិងរៀន និងសេវាអប់រំកុមារតូច របស់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ (៣) ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវចុះពិនិត្យតាមដានដំណើរការអនុវត្តការបង្រៀននិងរៀន និងសេវាអប់រំកុមារតូចក្រោមវិសាលភាពគ្រប់គ្រងរបស់ខ្លួន (៤) នាយក នាយិកា គឺត្រូវចុះពិនិត្យតាមដានថ្នាក់រៀនជាប្រចាំនិងត្រូវដើរតួជាអ្នកដឹកនាំការបង្រៀននិងរៀន និងជាអធិការអេចិន្ត្រៃយ៍ ដោយការរៀបចំផែនការច្បាស់លាស់ក្នុងការជួយគ្រូឱ្យបង្រៀនបានទាន់ពេលវេលា (ក្រសួងអយក, ២០២១ឧ)។ ការបូកសរុប និងការរៀបចំរបាយការណ៍ គ្រប់សាលារៀន ត្រូវបញ្ជូនរបាយការណ៍មកការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយគ្រប់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺត្រូវរៀបចំបូកសរុបរបាយការណ៍មកមន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត។ បន្ទាប់មក គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត គឺត្រូវបូកសរុបរបាយការណ៍ផ្ញើមកក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានអប់រំកុមារតូច)។ ការរៀបចំរបាយការណ៍នេះ មានបីដំណាក់កាល រួមមាន (១)ការរៀបចំរបាយការណ៍បវេសនកាល (២)ការរៀបចំរបាយការណ៍ឆមាសទី១ និង(៣)ការរៀបចំរបាយការណ៍ឆមាសទី២ និងដំណាច់ឆ្នាំ (ក្រសួងអយក, ២០២១ឧ)។

ដើម្បីអនុវត្តកិច្ចការទាំងអស់នេះបាន ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ គ្រឹះស្ថានមត្តេយ្យសិក្សា ព្រមទាំងអ្នកផ្តល់សេវាអប់រំកុមាតូចទាំងអស់ នូវសារាចរណ៍ណែនាំមួយចំនួន រួមមាន (១)ក្នុងពេលប្រព្រឹត្តទៅនៃដំណើរការឆ្នាំសិក្សា គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា និងអ្នកផ្តល់សេវាអប់រំកុមារតូចគ្មានសិទ្ធិបិទគ្រឹះស្ថានសិក្សា និងកន្លែងផ្តល់សេវាអប់រំកុមារតូចដោយគ្មានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡានោះទេ ទោះបីក្នុងប្រការណាក៏ដោយ (២)ក្នុងករណីប្រធានសក្តិដូចជាទឹកជំនន់ ខ្យល់ព្យុះ ជាដើម នាយកនាយិកាសាលារៀន ត្រូវធ្វើរបាយការណ៍បន្ទាន់ជូនក្រសួងអប់រំ យុវជន និងកីឡា ដោយការឯកភាពពីការិយាល័យអប់រំ និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ដើម្បីសុំការអនុញ្ញាត្តផ្អាកដំណើរការសិក្សាបណ្តោះអាសន្ន (ក្រសួងអយក, ២០១២) (៣)គ្រប់សាលារៀន ត្រូវពង្រឹងការអនុវត្តកាលវិភាគ វិមជ្ឈការកាលវិភាគ និងប្រតិទិនសិក្សាឱ្យបានត្រឹមត្រូវ ចៀសវាងបាតុភាពឈប់ ឬបិទសាលារៀនមុនពេលកំណត់ និងចូលរៀនក្រោយពេលកំណត់ដោយអនុវត្តតាមស្មារតី (ក្រសួងអយក, ២០១៩) (៤) គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា និងអ្នកផ្តល់សេវាអប់រំកុមារតូចទាំងអស់ដោយផ្តោតការយកចិត្តទុកដាក់អនុវត្តយ៉ាងហ្មត់ចត់នូវគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) ក្នុងបរិបទ កូវីដ-១៩ ជាពិសេសពង្រឹងវិធានការពារ ទប់ស្កាត់ និងឆ្លើយតបការ

រីករាលដាលកូវីដ-១៩ របស់ក្រសួងសុខាភិបាល (៥)ការងារគ្រប់គ្រងរដ្ឋបាល និងស្ថិតិ (៦)ការគ្រប់គ្រងវត្តមានបុគ្គលិកអប់រំ និងកុមារក្នុងដំណើរការសិក្សា (៧)ការរៀបចំស្វ័យវាយតម្លៃសាលារៀន និងកម្មវិធី (៨) តួនាទី និងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងសាលាមត្តេយ្យសិក្សា/ក្រុមប្រឹក្សាឃុំសង្កាត់ និង(៩)ការរៀបចំផែនការ (ក្រសួងអយក, ២០២១e)។

## ២.៤.១ ការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សាសាធារណៈ និងឯកជន

ការគ្រប់គ្រងសេវាអប់រំកុមារតូច នៅមត្តេយ្យសិក្សាសាធារណៈ និងឯកជន គឺសំដៅដល់ការគ្រប់គ្រងរដ្ឋបាល និងស្ថិតិ។ សម្រាប់សាលាមត្តេយ្យសិក្សាដាច់ដោយឡែក នាយក នាយិកា គឺត្រូវរៀបចំបញ្ជី និងសំណុំលិខិតនានា ទុកដាក់តាមប្រភេទ និងពេលវេលា និងរៀបចំសំណុំលិខិតរបស់បុគ្គលិកម្នាក់ៗឱ្យបានត្រឹមត្រូវដោយការរៀបចំក្រុមបណ្តាញសាលារៀនក្នុងការកែលម្អផែនទីសិក្សាសាលារៀន និងគ្រប់គ្រងប្រព័ន្ធលំហូរទិន្នន័យយកព័ត៌មានកុមារចូលរៀន (ក្រសួងអយក, ២០២១f)។ គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា និងអ្នកផ្តល់សេវាអប់រំកុមារតូច គឺត្រូវបែងចែកភារកិច្ចទទួលខុសត្រូវក្នុងការផ្សព្វផ្សាយ និងការធ្វើយុទ្ធនាការប្រមូលកុមារចូលរៀនចាប់ពីអាយុ៣ឆ្នាំ ឬ៣៦ខែ រហូតដល់អាយុក្រោម៦ឆ្នាំ ឬយ៉ាងខ្ពស់៧០ខែ និងគិតត្រឹមថ្ងៃកំណត់ចូលសិក្សារបស់គ្រឹះស្ថានមត្តេយ្យសិក្សាការចូលរៀនដោយការចងបដា និងពាក្យស្លោក នៅតាមទីប្រជុំជន និងតាមរូបភាពផ្សេងៗទៀតដោយធ្វើការអំពាវនាវដល់មាតាបិតា ឬអ្នកអាណាព្យាបាល ដើម្បីនាំកូនដក់អាយុមកចុះឈ្មោះចូលរៀនគ្រប់គ្នា។ គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា និងអ្នកផ្តល់សេវាអប់រំកុមារតូច ត្រូវចាប់ទទួលកុមារចូលរៀនឆ្នាំសិក្សាថ្មីគ្រប់កម្រិតថ្នាក់ រួមទាំងកុមារពិការ និងកុមារជនជាតិដើមភាគតិច (ក្រសួងអយក, ២០២១g)។ គ្រឹះស្ថានមត្តេយ្យសិក្សា ត្រូវផ្សព្វផ្សាយសេចក្តីណែនាំ និងសារាចរនានាដែលពាក់ព័ន្ធ និងកំពុងស្ថិតនៅជាធរមានជាពិសេសច្បាប់ស្តីពីការអប់រំក្របសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ប្រកាសស្តីបទបញ្ជាផ្ទៃក្នុងសម្រាប់មត្តេយ្យសិក្សា សារាចរណែនាំស្តីពីការអនុវត្ត។ គណៈគ្រប់គ្រងមត្តេយ្យសិក្សា ត្រូវប្រជុំគ្រូបន្ទុកថ្នាក់ស្តីពីការរៀបចំរដ្ឋបាលថ្នាក់រួមមាន បទបញ្ជាផ្ទៃក្នុង បញ្ជីសាពើភណ្ឌ និងតារាងផ្សេងៗទៀតដោយយកទៅបិទតាមថ្នាក់រៀនមុនពេលដំណើរការសិក្សា រៀបចំស្ថិតិកុមារឱ្យបានត្រឹមត្រូវតាមប្រភេទកុមារ ដូចជា ពិការ ក្រីក្រ កំព្រា ជួបការលំបាក និងកុមារជនជាតិដើមភាគតិចធ្វើតារាងរាយនាមបុគ្គលិកអប់រំតាមតួនាទីភារកិច្ច អតីតភាពការងារ ព្រមទាំងរៀបចំសំណុំលិខិតរបស់បុគ្គលិកអប់រំម្នាក់ៗឱ្យបានត្រឹមត្រូវ និងណែនាំគ្រូពង្រៀនគ្រប់កម្រិតថ្នាក់ឱ្យរៀបចំបញ្ជីហៅឈ្មោះកុមារ ដោយសរសេរប្រវត្តិរូបសង្ខេបរបស់កុមារម្នាក់ៗឱ្យ

បានត្រឹមត្រូវ និងរៀបចំសៀវភៅរដ្ឋបាលតាមការណែនាំ (ក្រសួងអយក, ២០២១h)។ គ្រឹះស្ថានមត្តេយ្យសិក្សាគឺត្រូវរៀបចំឯកសាររដ្ឋបាលឱ្យមានសណ្ដាប់ធ្នាប់ទៅតាមប្រភេទ ពេលវេលា ដែលងាយស្រួលក្នុងការរក្សាទុក និងស្វែងរក។ ថ្នាក់មត្តេយ្យសិក្សាឯកជន ត្រូវរៀបចំស្ថិតិកុមារឱ្យបានត្រឹមត្រូវ និងប្រភេទកុមារដូចជា ពិការ ក្រីក្រ កំព្រា ជួបការលំបាក និងកុមារជនជាតិដើមភាគតិចនិងបញ្ជូនមកការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុកខណ្ឌឱ្យបានតាមកាលកំណត់ (ក្រសួងអយក, ២០២១j)។ ការគ្រប់គ្រងវត្តមានបុគ្គលិកអប់រំ និងកុមារក្នុងដំណើរការសិក្សា គឺត្រូវពង្រឹង និងជំរុញការអនុវត្តសេចក្ដីណែនាំ និងសារាចរនានាដែលពាក់ព័ន្ធ និងកំពុងនៅជាធរមាន ពិសេសច្បាប់ស្ដីការអប់រំ ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ប្រកាសស្ដីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ រៀបចំ និងជំរុញដំណើរការសាលារៀនឱ្យបានទៀងទាត់ ដោយពិនិត្យជាប្រចាំពីពេលវេលាបិទ បើក និងចេញ ចូលថ្នាក់រៀន និងប្រើប្រាស់បញ្ជីហៅឈ្មោះកុមារឱ្យបានត្រឹមត្រូវដោយចុះចំនួនវត្តមានពិតប្រាកដ ទៅតាមថ្ងៃសិក្សា និងធ្វើអត្រាភាគរយអវត្តមានកុមារក្នុងខែនីមួយៗ ដោយមានចុះទិដ្ឋាការពីនាយក នាយិកាសាលារៀន (ក្រសួងអយក, ២០២១k)។ ការរៀបចំស្វ័យវាយតម្លៃសាលារៀន/ថ្នាក់រៀន គឺត្រូវរៀបចំស្វ័យវាយតម្លៃឱ្យបាន២ដង ក្នុង១ឆ្នាំសិក្សា នៅដំណាច់ឆមាសទី១ និងដំណាច់ឆមាសទី២។ បុគ្គលិកអប់រំនៃគ្រឹះស្ថានសិក្សាទាំងអស់ ត្រូវរៀបចំស្វ័យវាយតម្លៃការងារឱ្យបានទៀងទាត់ជារៀងរាល់ឆមាស ដោយប្រើឧបករណ៍វាយតម្លៃស្ដង់ដាអប្បរមាសាលា/ថ្នាក់ នៅក្នុងសៀវភៅប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យការអប់រំកុមារតូច និងគោលការណ៍នៃនាំពាក់ព័ន្ធជាធរមាន ដើម្បីធ្វើស្វ័យវាយតម្លៃ និងកែលម្អសាលារៀន/ថ្នាក់រៀនជាប្រចាំ (ក្រសួងអយក, ២០១៧)។ ក្នុងការរៀបចំផែនការ គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គឺត្រូវលើកគម្រោងប្រើប្រាស់ថវិកាកម្មវិធី (PB) ឱ្យបានសមស្របតាមតម្រូវការតាមជំពូកគណនី និងតាមមាតិកាថវិកាថ្មី (ក្រសួងសហវ, ២០១៣) និងគោលការណ៍ណែនាំស្ដីការគ្រប់គ្រងមូលនិធិដំណើរការតាមសាលារៀនសាធារណៈ (ក្រសួងអយក, ២០១៨)។ ក្នុងការគ្រប់គ្រងការសិក្សាមត្តេយ្យសិក្សាសាធារណៈ និងមត្តេយ្យសិក្សាឯកជន ត្រូវអនុវត្តការបង្រៀន និងរៀនឱ្យបានពេញលេញចំនួន៣៥សប្ដាហ៍ ស្មើនឹង១០៥០ម៉ោង ក្នុងមួយឆ្នាំសិក្សា និង៣០ម៉ោងក្នុងមួយសប្ដាហ៍១ម៉ោងសិក្សាស្មើនឹង៣០នាទី តាមកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ហើយត្រូវរៀបចំផែនការបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំខែ និងសប្ដាហ៍ ផែនការបង្រៀនប្រចាំថ្ងៃ និងធ្វើកិច្ចតែងការបង្រៀនគ្រប់មុខវិជ្ជាឱ្យបានត្រឹមត្រូវតាមការកំណត់ក្នុងកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា (ក្រសួងអយក, ២០២១L)។ មត្តេយ្យសិក្សា ត្រូវរៀបចំថ្នាក់រៀនតាមស្ដង់ដា ផលិតសម្ភារឧបទេសជំនួយការបង្រៀន និងស្រាវជ្រាវវិធី

សាស្ត្របង្រៀន ផែនការបង្រៀនសម្រាប់ជួយកុមាររៀនយឺត។ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ ត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីសិក្សាប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ (ក្រសួងអយក, ២០២១m)។ ការរៀបចំកាលវិភាគសិក្សា គឺជាការរៀបចំកាលវិភាគសិក្សាដោយពេលព្រឹកចូលនៅម៉ោង៧:០០ និងចេញនៅម៉ោង ១០:៣០នាទី ក្នុងករណីសាលារៀន អនុវត្តការបង្រៀនពីរពេលៈពេលព្រឹកចូលរៀននៅម៉ោង៧:០០ ចេញនៅម៉ោង ១០:៣០នាទី ពេលរសៀលចូលរៀននៅម៉ោង១៣:០០ ចេញនៅម៉ោង១៦:៣០នាទី (ក្រសួងអយក, ២០២១n)។ ចំពោះថ្នាក់មត្តេយ្យសិក្សាដែលស្ថិតនៅជាមួយសាលាបឋមសិក្សា ត្រូវអនុវត្តការចេញលេងតាមសាលាបឋមសិក្សា។ ការអនុវត្តកាលវិភាគសិក្សារបស់សាលារៀននីមួយៗ ត្រូវមានការទន់ភ្លន់ បត់បែនទៅតាមបរិបទជាក់ស្តែងរបស់មូលដ្ឋាន (ក្រសួងអយក, ២០២១o)។ ការវាយតម្លៃការសិក្សារបស់កុមារ និងសមត្ថភាពមាតាបិតា ត្រូវរៀបចំដំណើរការវាយតម្លៃលទ្ធផលសិក្សារបស់កុមារនិងសមត្ថភាពមាតាបិតាដោយអនុលោមតាមកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា និងកម្មវិធីអប់រំមាតាបិតា (ក្រសួងអយក, ២០២១p)។ ចំពោះរបៀបរបបនៃដំណើរការអនុវត្តការវាយតម្លៃ អាស្រ័យទៅលើស្វ័យចាត់ចែងដឹកនាំទាងស្រុងតាមស្ថានភាពជាក់ស្តែង ប្រកបដោយភាពបត់បែនរបស់គ្រឹះស្ថានមត្តេយ្យសិក្សានីមួយៗ។ លទ្ធផលវាយតម្លៃសមត្ថភាពកុមារ និងមាតាបិតា ជាកម្មវត្ថុសម្រាប់រៀបចំផែនការសកម្មភាពជួយកុមាររៀនយឺតនិងមាតាបិតា។ ការបង្រៀន និងរៀនតាមគន្លងប្រក្រតីភាពថ្មី គឺត្រូវធ្វើការណែនាំគ្រូបង្រៀនតាមកម្រិតថ្នាក់ឱ្យអនុវត្តគោលការណ៍សម្រាប់កម្មវិធីមត្តេយ្យសិក្សា។ ការបង្រៀននិងរៀនត្រូវអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល និងគោលវិធីចម្រុះ ការសិក្សារបស់កុមារត្រូវធ្វើឡើងតាមកាលេង និងសហការ។ កុមារ ត្រូវបានផ្តល់ទំនុកចិត្តការលើកទឹកចិត្ត និងការទទួលខុសត្រូវក្នុងការរៀនសូត្រប្រកបដោយសុវត្ថិភាព និងភាពកក់ក្តៅ។ ក្នុងអន្តរកម្មនៃកាសិក្សាប្រកបដោយគុណភាព កុមារនឹងទទួលបានចំណេះដឹង បំណិន និងឥរិយាបទថ្មីៗបន្ថែមទៀតពីបរិស្ថានសិក្សារបស់ខ្លួន កុមារជាអ្នកកសាងសមត្ថភាពដោយខ្លួនឯង គ្រូជាអ្នកណែនាំ និងសម្របសម្រួល ដើម្បីឱ្យកុមាររៀនសូត្របានល្អប្រសើរ (Lambros, 2002)។ ការរៀបចំកិច្ចតែងការបង្រៀន ត្រូវរៀបចំតាមគោលវិធីចម្រុះ បង្កើតតាមដានការរៀនសូត្ររបស់កុមារប្រកបដោយប្រសិទ្ធភាព។ ការរៀន និងបង្រៀន ត្រូវដំណើរការស្របតាមអាយុ វប្បធម៌ និងសមធម៌ ត្រូវមានលក្ខណៈជាក់ស្តែង និងវិទ្យាសាស្ត្រ។ សាលារៀន និងគ្រូបង្រៀន គឺត្រូវធ្វើអន្តរកម្មជាមួយអ្នកអាណាព្យាបាល សហគមន៍ និងអាជ្ញាធរមូលដ្ឋាន (Martins, A. B., & Marques, A., 2010)។ ក្នុងករណីស្ថានភាពជំងឺកូវីដ-១៩ នៅតែបន្តរីករាលដាល គ្រឹះស្ថានសិក្សាព្រមទាំងអ្នកផ្តល់សេវាអប់រំកុមារទាំងអស់ត្រូវអនុវត្តសេចក្តីណែនាំស្តីពីការបង្រៀននិងរៀនពីចម្ងាយនិតតាមប្រព័ន្ធអេឡិចត្រូនិច សម្រាប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងសេ

វាអប់រំកុមារតូច (ក្រសួងអយក, ២០២១q)។ ក្នុងការគ្រប់គ្រងបណ្ណាល័យមត្តេយ្យសិក្សាដែលមានបន្ទប់បណ្ណាល័យ ត្រូវរៀបចំបណ្ណាល័យដោយធ្វើការពិនិត្យមើលគុណភាពសៀវភៅ និងរៀបចំដាក់ឱ្យសមស្របតាមកម្រិតថ្នាក់ និងវ័យរបស់កុមារ រៀបចំតុបតែងបន្ទប់ឱ្យមានលក្ខណៈ៣យ៉ាង លក្ខណៈជាតិ លក្ខណៈគរុកោសល្យ និងលក្ខណៈសោភ័ណ រៀបចំបញ្ជីសោភណ្ឌ ស្តីពីសៀវភៅក្នុងបណ្ណាល័យ និងត្រូវមានដំណើរការជាប់ជាប្រចាំព្រមទាងរៀបចំឱ្យមាននូវចាន ដែក ធុងទឹក សាប៊ូ អាល់កុល ឬជែលសម្រាប់ឱ្យកុមារលាងដៃមុនចូលបណ្ណាល័យ។ សម្រាប់ការប្រជុំបច្ចេកទេសគ្រឹះស្ថានមត្តេយ្យសិក្សា ត្រូវអនុវត្តរបបប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ក្នុងមួយឆ្នាំសិក្សាចំនួន៣៥ពេល ដោយផ្តោតលើវិធីសាស្ត្របង្រៀននិងរៀន ការផលិតសម្ភារឧទ្ទេស ការធ្វើថ្នាក់និទស្សន៍ ការពិភាក្សាលើកិច្ចតែងការបង្រៀន ការរៀបចំបណ្ណសង្កេតសមត្ថភាពកុមារប្រចាំសប្តាហ៍ (ក្រសួងអយក, ២០២១r)។ ការរៀបចំបណ្ណសកម្មភាព និងបង្រៀនបែបថ្មី និងកម្មវិធីសិក្សាជាដើម គឺសំដៅឱ្យការសិក្សារបស់កុមារសម្រេចជោគជ័យឆ្លើយតបនឹងលទ្ធផលរំពឹងទុក។ ការប្រជុំ ត្រូវអនុវត្តដូចជាគ្រឹះស្ថានមត្តេយ្យសិក្សាដាច់ដោយឡែកត្រូវប្រជុំតាមគ្រឹះស្ថានសិក្សារៀងៗខ្លួនមត្តេយ្យសិក្សានៅជាមួយសាលាបឋមសិក្សាត្រូវប្រជុំពីរដងជា មួយកម្រងសាលារៀន និងពីរដងជាមួយសាលារៀនផ្ទាល់របស់ខ្លួនក្នុងមួយខែ។ រាល់ការប្រជុំ ត្រូវរៀបចំឱ្យមានរបៀបវារៈកំណត់ហេតុច្បាស់លាស់ដោយឆ្លុះបញ្ចាំងបញ្ហាពាក់ព័ន្ធនានា និងទិសដៅដែលត្រូវអនុវត្តក្នុងខែបន្ទាប់តាមកម្រិតថ្នាក់ រាល់ការប្រជុំ ពេលវេលា និងទីកន្លែង ដែលមានភាពបត់បែនតាមមូលដ្ឋានជាក់ស្តែង (ក្រសួងអយក, ២០២១s)។ ការប្រជុំបច្ចេកទេសទាំង៣៥ពេល គឺទទួលបានការឧបត្ថម្ភថវិកាមានចំនួន១៤ពេលប៉ុណ្ណោះ។ សម្រាប់ការគ្រប់គ្រងធនធានមនុស្ស គណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា និងអ្នកផ្តល់សេវាអប់រំកុមារតូច ត្រូវរៀបចំធ្វើបំណែងចែកភារកិច្ចទទួលខុសត្រូវក្នុងការផ្សព្វផ្សាយ ធ្វើយុទ្ធនាកាប្រមូលកុមារចូលរៀនចាប់ពីអាយុ៣ឆ្នាំ ដល់ក្រោម៦ឆ្នាំ ចាត់ឱ្យមានអ្នកទទួលកុមារចូលរៀនឆ្នាំសិក្សាថ្មីគ្រប់កម្រិតថ្នាក់ និងម្នាក់ទៀតឱ្យទទួលខុសត្រូវលើកិច្ចការរដ្ឋបាលសាលារៀន បែងចែកគ្រូទទួលបន្ទុកតាមថ្នាក់ និងជ្រើសរើសតែងតាំងប្រធានក្រុមបច្ចេកទេសតាមកម្រិតថ្នាក់ ដើម្បីធានាបានទាងការបង្រៀននិងរៀននៅក្នុងសាលារៀន (ក្រសួងអយក, ២០២១t)។ គ្រឹះស្ថានមត្តេយ្យសិក្សា គួរតែធ្វើការប្រជុំណែនាំគ្រូឱ្យចេះប្រប្រាស់ព័ត៌មានសារគមនាគមន៍ និងបច្ចេកវិទ្យា ( ICT ) និងតាមដានការបង្រៀនតាមទូរទស្សន៍ វេបសាយរបស់ក្រសួងអប់រំ យុវជន និងកីឡា បណ្តាញសង្គមដោយការរៀបចំឱ្យមានអ្នកជួយបណ្តុះបណ្តាលផ្នែកព័ត៌មានសារគមនាគមន៍ និងបច្ចេកវិទ្យា (ICT) តម្រង់ទិស និងបំប៉នសមត្ថភាពគណៈគ្រប់គ្រងមត្តេយ្យសិក្សា គ្រូបង្រៀន និងអ្នកផ្តល់សេវាអបរំកុមារតូចស្តីពីវិធីសាស្ត្របង្រៀនថ្មីៗ ផ្សព្វផ្សាយដល់បុគ្គលិកអប់រំទាំងអស់ក្នុងសាលារៀនឱ្យយល់ដឹងកាន់តែច្បាស់ពីការប្រើប្រាស់ឧបករណ៍នៃប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ

ផ្អែកលើលទ្ធផលពីរបៀបប្រមូល និងបញ្ចូលទិន្នន័យនៅក្នុងឧបករណ៍ និងបែងចែកតារាងទិន្នន័យ ពិសេសស្តង់ដាអប្បរមាសាលា/ថ្នាក់ឱ្យដល់បុគ្គលិកទាំងអស់នៅពេលប្រជុំ មុនដំណើរការសិក្សា ដើម្បីប្រើប្រាស់ស្របតាមក្របខណ្ឌពេលវេលា។ ក្នុងការវាយតម្លៃការបំពេញការងារ គណៈគ្រប់គ្រងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងអ្នកផ្តល់សេវាអប់រំកុមារតូចទាំងអស់ ត្រូវធ្វើការវាយតម្លៃការអនុវត្តការងាររបស់គ្រូបង្រៀនឱ្យបាន២ដងក្នុង១ឆ្នាំសិក្សា ដំណាច់ឆមាសទី១ និងដំណាច់ឆមាសទី២ ដោយការប្រើប្រាស់ឧបករណ៍វាយតម្លៃស្តង់ដាអប្បរមាថ្នាក់ ដែលមានក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល (ក្រសួងអយក, ២០២១t)។ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ គ្រប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងទីកន្លែងផ្តល់សេវាអប់រំកុមារតូចទាំងអស់ គឺត្រូវធ្វើបច្ចុប្បន្នភាពគ្រប់គ្រងហិរញ្ញវត្ថុសាលារៀន ដើម្បីរក្សាបាននូវតម្លាភាព និងគណនេយ្យភាពក្នុងគ្រឹះស្ថានសិក្សា គឺត្រូវមានបញ្ជីចំណូល ចំណាយ ផ្សព្វផ្សាយនៅក្នុងគ្រឹះស្ថានសិក្សា។

### ២.៤.២ ការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សាសហគមន៍

មណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍ គឺជាទីកន្លែងដែលបង្កើត និងគាំទ្រដោយក្រុមប្រឹក្សាឃុំ/សង្កាត់ សម្រាប់ការប្រមូលកុមារអាយុពី៣ឆ្នាំ ដល់ក្រោម៦ឆ្នាំ ទទួលបានសេវាអប់រំ និងជាកន្លែងមួយដែលជាទីមេត្រីរបស់កុមារគ្រប់រូបចង់បាន (នា.អកត, ២០១៨c)។ ដើម្បីឱ្យស្របតាមនិន្នាការបច្ចុប្បន្ន និងដំណើរការការងារមត្តេយ្យសិក្សាសហគមន៍ មានភាពរលូន និងមាននិរន្តរភាព ភូមិ/ឃុំសង្កាត់ណាដែលបង្កើតមត្តេយ្យសិក្សាសហគមន៍ ត្រូវបង្កើតកម្មវិធីអប់រំមាតាបិតា ជាពិសេសសម្រាប់មាតាបិតា អ្នកអាណាព្យាបាល អ្នកគ្រប់គ្រងថែរក្សាដែលមានកូនរៀននៅថ្នាក់ មត្តេយ្យសិក្សាសហគមន៍ បានយល់ដឹងពីដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារតូច ការថែទាំផ្ទៃពោះ ការថែទាំគាំពារកូន និងខ្លួនឯង ការផ្តល់អាហារូបត្ថម្ភ និងការប្រើប្រាស់សេវាសុខាភិបាល គ្រួសារ និងសហគមន៍។

ដើម្បីឱ្យការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សាសហគមន៍ល្អប្រសើរ និងប្រកបដោយគុណភាព គណៈគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ និងអ្នកផ្តល់សេវាអប់រំកុមារតូច ត្រូវមានវិធានការ និងគោលការណ៍ណែនាំច្បាស់លាស់។ភារកិច្ចគណៈកម្មការគ្រប់គ្រង និងគាំទ្រមត្តេយ្យសិក្សាសហគមន៍ ត្រូវប្រមូលទិន្នន័យព័ត៌មានកុមារអាយុសូន្យឆ្នាំ ទៅក្រោម៦ឆ្នាំ ពិសេសកុមារអាយុ៣ឆ្នាំ ដល់ក្រោម៦ឆ្នាំ ដែលមិនទាន់បានទទួលសេវាថែទាំ និងអប់រំកុមារតូច រៀបចំផែនការបង្កើត និងអភិវឌ្ឍន៍មត្តេយ្យសិក្សាសហគមន៍ ជ្រើសរើសភូមិ និងទីកន្លែងសម្រាប់បង្កើតមត្តេយ្យសិក្សាសហគមន៍ ជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍ រៀបចំការប្រជុំពិនិត្យ និងឯកភាពលើដំណើរការ

ថ្នាក់មត្តេយ្យសិក្សាសហគមន៍ ចុះពិនិត្យតាមដាន និងវាយតម្លៃការងាររបស់អ្នកផ្តត់ផ្គង់សេវាកម្ម/គ្រូមត្តេយ្យសិក្សាសហគមន៍ ផ្តល់ថវិកាឧបត្ថម្ភគ្រូមត្តេយ្យសិក្សាសហគមន៍ឱ្យបានសមស្រប និងបើកឱ្យទាន់ពេលវេលា ប្រជុំពិភាក្សាវាយតម្លៃលើរបាយការណ៍រីកចម្រើន និងរាយការណ៍ជូនមេឃុំ/ ចៅសង្កាត់ បំពេញទម្រង់ និងរបាយការណ៍តាមការណែនាំក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃរួចផ្ញើទៅគ្រប់អ្នកពាក់ព័ន្ធ ពិសេសការិយាល័យអប់រំ យុវជននិងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបូកសរុបលទ្ធផលការងារ ផ្តល់ការគាំទ្រដល់ដំណើរការមត្តេយ្យសិក្សាសហគមន៍ (នា.អកត, ២០១៨d)។

ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីអនុវត្តអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍។ អនុក្រឹត្យនេះ បានចែងអំពី(១)ប្រកាសស្តីពីការដាក់ឱ្យប្រើស្តង់ដាអប្បរមាមត្តេយ្យសិក្សាសហគមន៍ (២) ប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ (៣) ប្រកាសអន្តរក្រសួងស្តីពីគោលការណ៍ និងអត្រានៃការឧបត្ថម្ភមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា (៤) ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីបើកផ្តល់ និងទូទាត់ថវិកាឧបត្ថម្ភប្រចាំខែជូនគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ ថវិកាសម្រាប់កុមារ និងថវិកាដំណើរការនិងកិច្ចអភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ (៥) សេចក្តីប្រកាសស្តីពីការកំណត់លក្ខណៈសម្បត្តិសម្រាប់ប្រែក្លាយថ្នាក់មត្តេយ្យសិក្សាសហគមន៍ជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈ និង(៦) ប្រកាសស្តីពីការកំណត់យន្តការ នីតិវិធី និងលក្ខខណ្ឌនៃការជ្រើសរើសគ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍។

# ជំពូក ៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក ៣
# វិធីសាស្ត្រស្រាវជ្រាវ

ជំពូកទី៣ បានធ្វើការពន្យល់បកស្រាយអំពីការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ ការជ្រើសរើសសំណាក ប្រភពទិន្នន័យ ការប្រមូលទិន្នន័យរួមមាន (កម្រងសំណួរ និងសំណួរសម្ភាសន៍) ការវិភាគទិន្នន័យរួមមាន (ការវិភាគកម្រងសំណួរ និងការវិភាគសម្ភាសន៍) និងក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣.១ ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ (Gates, 2008) ដែលជាការរួមបញ្ចូលគ្នានៃគុណវិស័យ (Collins, 2018) និងបរិមាណវិស័យ (Guo, 2013) សម្រាប់ការប្រមូល និងវិភាគទិន្នន័យ។ ការសិក្សានេះបានប្រើប្រាស់ទិន្នន័យទី១ (Primary Data) សម្រាប់ការបកស្រាយលទ្ធផលស្រាវជ្រាវ។ វិធីសាស្ត្រប្រមូលទិន្នន័យនៃការស្រាវជ្រាវ រួមមានសម្ភាសន៍ផ្ទាល់ (Griffee, 2005) និងកម្រងសំណួរ (Kabir, 2016)។ វិធីសាស្ត្រវិភាគទិន្នន័យនៃការសិក្សាស្រាវជ្រាវ រួមមានការវិភាគបែបគុណវិស័យ និងបរិមាណវិស័យ។ សម្រាប់ការវិភាគបែបគុណវិស័យ អ្នកស្រាវជ្រាវបានប្រើប្រាស់ការវិភាគបែបខ្លឹមសារ (Harwood, 2003)។ សម្រាប់ការវិភាគបែបបរិមាណវិស័យ អ្នកស្រាវជ្រាវបានប្រើប្រាស់ការវិភាគពណ៌នាស្ថិតិ (Horton, 2005)។

## ៣.២ ការជ្រើសរើសសំណាក

យោងលិខិតលេខ២៣៤១ អយក.វជអ ចុះថ្ងៃសុក្រ ១៣កើត ខែចេត្រ ឆ្នាំខាលចត្វាស័ក ពស.២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ស្តីពីការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់ការសិក្សា គឺបានជ្រើសរើសសំណាកដែលអ្នកចូលរួមក្នុងការស្រាវជ្រាវចំនួន៤២៨នាក់ ស្រីចំនួន ២៦៦នាក់។ អ្នកស្រាវជ្រាវ បានកំណត់ជ្រើសរើសអ្នកចូលរួមនៃការសិក្សាស្រាវជ្រាវនៅតាមសាលាគោលដៅ នៃក្រុង/ស្រុកចំនួន ១៤ ក្នុងខេត្តបាត់ដំបង ដើម្បីប្រមូលទិន្នន័យ។ អ្នកសិក្សាស្រាវជ្រាវ បានកំណត់ជ្រើសរើសសំណាកនៅខេត្តបាត់ដំបង ព្រោះខេត្តបាត់ដំបងជាខេត្តគោលដៅនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលថ្នាក់ក្រុង/ស្រុក។ ការសិក្សាបានជ្រើសរើសគណៈគ្រប់គ្រងថ្នាក់មន្ទីរអប់រំ យុវជន និងកីឡា និងមន្ត្រីជំនាញអប់រំកុមារតូច ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុងស្រុកចំនួន ១៦នាក់ ស្រីចំនួន ១៥នាក់ និងគណៈគ្រប់គ្រងមត្តេយ្យសិក្សាចំនួន៦៥នាក់ ស្រីចំនួន

២៦នាក់ (គណៈគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ចំនួន៣៦នាក់ ស្រី ០នាក់ មត្តេយ្យសិក្សាដាច់ដោយឡែកចំនួន២៦ នាក់ ស្រីចំនួន ២៦នាក់ និងថ្នាក់មត្តេយ្យក្នុងសាលាបឋមសិក្សា ៣នាក់ ស្រី ០នាក់)។ ការសិក្សានេះ ក៏បានជ្រើសរើសគ្រូបង្រៀននៅមត្តេយ្យសិក្សាចំនួន១៥២នាក់ ស្រីចំនួន ១៥១នាក់ (គ្រូបង្រៀននៅមត្តេយ្យសិក្សាសហគមន៍ចំនួន ៤៥នាក់ ស្រីចំនួន ៤៥នាក់ និងមត្តេយ្យសិក្សាសាធារណៈចំនួន១០៧នាក់ ស្រីចំនួន ១០៦នាក់)។

## ៣.៣ ប្រភេទទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់ប្រភេទទិន្នន័យបឋម (Primary data) សម្រាប់ការបកស្រាយលទ្ធផលស្រាវជ្រាវ។ ការសិក្សានេះ ក៏បានប្រើប្រាស់កម្រងសំណួរ និងសម្ភាសន៍ផ្ទាល់ក្នុងការប្រមូលទិន្នន័យ ស្រាវជ្រាវ ដើម្បីសិក្សាពីការគ្រប់គ្រង និងការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក និងស្វែងយល់ពីផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។

## ៣.៤ ការប្រមូលទិន្នន័យ

### ៣.៤.១ កម្រងសំណួរ

ការសិក្សានេះ បានប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យ។ មុនពេលចាប់ផ្តើមប្រមូលទិន្នន័យដោយកម្រងសំណួរ អ្នកស្រាវជ្រាវបានធ្វើបទបង្ហាញពីប្រធានបទ និងគោលបំណងនៃការស្រាវជ្រាវ។ បន្ទាប់មកអ្នកស្រាវជ្រាវ បានកំណត់ចំនួនអ្នកចូលរួម (៤២៨នាក់) ដោយការជ្រើសរើសអ្នកដែលពាក់ព័ន្ធប្រធានបទស្រាវជ្រាវ។ ក្រោយពេលកំណត់ចំនួន និងជ្រើសរើសអ្នកចូលរួមរួចហើយ អ្នកស្រាវជ្រាវបានចែកកម្រងសំណួរដល់អ្នកពាក់ព័ន្ធដើម្បីឆ្លើយសំណួរ។ ចម្លើយទាំងនោះ ត្រូវបានប្រមូល និងរក្សាទុកក្នុងការវិភាគ និងបកស្រាយលទ្ធផលស្រាវជ្រាវដើម្បីសិក្សាពីការគ្រប់គ្រង និងការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក និងស្វែងយល់ពីផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុកក្នុងការលើកកម្ពស់គុណភាពអប់រំ។

### ៣.៤.២ សំណួរសម្ភាសន៍

ការសិក្សា បានប្រើប្រាស់សំណួរសម្ភាសន៍ក្នុងការប្រមូលទិន្នន័យ។ ក្រោយពេលការធ្វើកម្រងសំណួរបានមួយសប្តាហ៍ អ្នកស្រាវជ្រាវបានជ្រើសរើសអ្នកចូលរួមដោយការជ្រើសរើសលក្ខណៈពីរយ៉ាង រួមមាន ការសិក្សាពីអ្នកពាក់ព័ន្ធនៃការគ្រប់គ្រង និងផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក និងអ្នកទទួលផលនៃការផ្ទេរសេវាអប់រំនេះ។ ក្រោយការជ្រើសរើសអ្នកចូលរួមចំនួន១០០នាក់ (គណៈគ្រប់គ្រង ២០នាក់ គ្រូបង្រៀន៣៥នាក់ និងមាតាបិតា

ឬអ្នកអាណាព្យាបាលកុមារ ៤៥នាក់) រួចហើយ អ្នកស្រាវជ្រាវបានសម្ភាសន៍អ្នកដែលត្រូវបានជ្រើសរើស។ នៅពេលសម្ភាសន៍អ្នកស្រាវជ្រាវ បានថតសម្លេងនៃការសម្ភាសន៍នោះដោយការអនុញ្ញាតពីអ្នកដែលត្រូវបានសម្ភាសន៍។ ក្រោយការសម្ភាសន៍នោះបានបញ្ចប់ អ្នកស្រាវជ្រាវបានប្រមូល និងរក្សាទុកនូវទិន្នន័យទាំងនោះសម្រាប់វិភាគ និងបកស្រាយលទ្ធផលស្រាវជ្រាវ ដើម្បីសិក្សាស្វែងយល់ពីការគ្រប់គ្រង និងការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុកក្នុងការលើកកម្ពស់គុណភាពអប់រំ។

## ៣.៥ ការវិភាគទិន្ន័យ

ការសិក្សានេះ បានប្រើប្រាស់កម្រងសំណួរ និងសម្ភាសន៍ផ្ទាល់ក្នុងការវិភាគទិន្នន័យស្រាវជ្រាវ ដើម្បីសិក្សាពីការគ្រប់គ្រង និងការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក និងស្វែងយល់ពីផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុកក្នុងការលើកកម្ពស់គុណភាពអប់រំ។ ដោយផ្អែកលើចម្លើយដែលបានទទួលមកពីការបំពេញកម្រងសំណួរ និងរួមទាំងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា មន្ត្រីជំនាញ ការិយាល័យអប់រំកុមារតូច នៃមន្ទីរអប់រំ យុវជន និងកីឡា ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុក នាយក នាយិកាសាលា ថ្នាក់មត្តេយ្យសិក្សាសាធារណៈ គណៈគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ គ្រូមត្តេយ្យសិក្សា និងមាតាបិតា ឬអ្នកអាណាព្យាបាលកុមារអាយុ៥ឆ្នាំ ការវិភាគទិន្នន័យបានធ្វើឡើងដោយការប្រើប្រាស់វិធីសាស្ត្របែបវិភាគតាមបរិមាណវិស័យ និងគុណវិស័យ។ ការសិក្សាស្រាវជ្រាវនេះ បានអនុវត្តការវិភាគតាមបែបស្ថិតិមានដូចជា និងការវិភាគបែបពណ៌នាតាមរយៈតារាង ដើម្បីរកឃើញអំពីការគ្រប់គ្រង និងការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក និងស្វែងយល់ពីផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។

### ៣.៥.១ ការវិភាគកម្រងសំណួរ

ការសិក្សានេះ បានប្រើប្រាស់ចម្លើយដែលទទួលបានពីការឆ្លើយកម្រងសំណួររបស់អ្នកចូលរួម សម្រាប់ការវិភាគ និងការបកស្រាយទិន្នន័យ។ ទិន្នន័យនៃកម្រងសំណួរ ត្រូវបានធ្វើការសំអាត រៀបចំបែងចែកទៅតាមប្រភេទបញ្ហា និងបកស្រាយដាក់ក្នុងតារាងទិន្នន័យ។ ទិន្នន័យនៃកម្រងសំណួរទាំងនោះ ត្រូវបានវិភាគដោយការប្រើប្រាស់វិធីសាស្ត្រវិភាគបែបពណ៌នាស្ថិតិដោយការប្រើប្រាស់ប្រព័ន្ធ SPSS ដើម្បីសិក្សាពីភាគរយ(%)លើផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។

### ៣.៥.២ ការវិភាគសម្ភាសន៍

ការសិក្សានេះ បានប្រើប្រាស់ចម្លើយដែលទទួលបានពីការឆ្លើយសំណួរសម្ភាន៍របស់អ្នកចូលរួមចំនួន១០០នាក់ សម្រាប់ការវិភាគ និងការបកស្រាយទិន្នន័យ។ ទិន្នន័យនៃសម្ភាសន៍ផ្ទាល់ ត្រូវបានធ្វើការសំអាត រៀបចំបែងចែកតាមប្រភេទបញ្ហា និងបកស្រាយដាក់ក្នុងតារាងទិន្នន័យ។ ទិន្នន័យនៃសម្ភាសន៍ផ្ទាល់ទាំងនោះ ត្រូវបានវិភាគដោយការប្រើប្រាស់វិធីសាស្ត្រវិភាគបែបខ្លឹមសារ ដើម្បីសិក្សាពីការគ្រប់គ្រង និងការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។

## ៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ

ដើម្បីរក្សាក្រមសីលធម៌ក្នុងការសិក្សាស្រាវ អ្នកស្រាវជ្រាវត្រូវប្រាប់ពីគោលបំណងនៃការស្រាវជ្រាវ រយៈពេលសុំសម្ភាសន៍ និងការសន្យាលើលក្ខខណ្ឌមួយចំនួន ដូចជា ការរក្សាការសម្ងាត់ជូនអ្នកចូលរួម ផ្តល់ព័ត៌មានដែលទទួលបានមិនត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀតឡើយ ការសម្ភាសន៍ត្រូវបានសុំការអនុញ្ញាត និងការឯកភាពពីអ្នកត្រូវសម្ភាសន៍។

# ជំពូក ៤

# លទ្ធផល និងការ
# ពិភាក្សា

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

ជំពូកទី៤ បានបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា។ លទ្ធផលស្រាវជ្រាវរួមមានការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក ការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា និងផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។ ការពិភាក្សាលើលទ្ធផលស្រាវជ្រាវមាន (១) យន្តការនៃការផ្ទេរសេវាអប់រំកុមារតូចនៅរដ្ឋបាលក្រុង-ស្រុក (២) យុទ្ធសាស្ត្រនៃការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា និង (៣) សារៈសំខាន់នៃការផ្ទេរសេវាអប់រំអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។

## ៤.១ លទ្ធផលស្រាវជ្រាវ

### ៤.១.១ ការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក

តារាង ៤.១ បានបង្ហាញពីទស្សនៈរបស់គណៈគ្រប់គ្រងចំពោះការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។ លទ្ធផលស្រាវជ្រាវបានង្ហាញថា ការអប់រំកុមារតូច សំដៅលើការអភិវឌ្ឍចំណេះដឹងរបស់កុមារតូចចាប់ពីអាយុសូន្យឆ្នាំទៅក្រោមអាយុ៦ឆ្នាំ។ យោងតាមលទ្ធផលស្រាវជ្រាវដែលបានបង្ហាញក្នុងតារាង ៤.១ ការផ្ទេរសេវាអប់រំកុមារតូចមានន័យថាការបង្វិតសេវាអប់រំទៅជិតអ្នកទទួលសេវាអប់រំ។ ការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក គឺជាកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការក្នុងវិស័យអប់រំ។ គោលបំណងនៃការផ្ទេរសេវាអប់រំកុមារតូច ពង្រីកសេវាអប់រំកុមារតូច បង្កើនស្វ័យភាពនៃការគ្រប់គ្រងសាលា ថ្នាក់មត្តេយ្យសិក្សា និងធានាប្រសិទ្ធភាពការអប់រំកុមារតូចនៅមត្តេយ្យសិក្សា។ យន្តការនៃការផ្ទេរសេវាការអប់រំកុមារតូច គឺជាការអនុវត្ត និងពិនិត្យតាមដាន។

ការផ្ទេរសេវាការអប់រំកុមារតូចក្នុងការលើកកម្ពស់គុណភាពអប់រំ បង្កើនការចុះឈ្មោះចូលរៀនរបស់សិស្សអភិវឌ្ឍវិធីសាស្ត្របង្រៀននិងរៀន និងធានាប្រសិទ្ធភាពនៃការគ្រប់គ្រង។ ប្រសិទ្ធភាពនៃការផ្ទេរសេវាការអប់រំកុមារតូច ជួយជំរុញលើកទឹកចិត្តការចូលរួមពីភាគីពាក់ព័ន្ធ ពង្រឹងការគ្រប់គ្រងសេវាអប់រំ និងអភិវឌ្ឍនិងលើកកម្ពស់គុណភាពអប់រំ។ សារៈប្រយោជន៍នៃការផ្ទេរសេវាការអប់រំកុមារតូចទៅមត្តេយ្យសិក្សា រួមមានកំណែទម្រង់ប្រព័ន្ធអប់រំ ការផ្សព្វផ្សាយសេវាអប់រំឱ្យបានទូលំទូលាយ ការធានាប្រសិទ្ធភាពនិងគុណភាពអប់រំ និងការស្វែងរកដៃគូអភិវឌ្ឍន៍ដើម្បីគាំទ្រសេវាអប់រំ។

| *តារាង ៤.១ ទស្សនៈគណៈគ្រប់គ្រងចំពោះការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក* | | |
|---|---|---|
| **ខ្លឹមសារ** | | **ចម្លើយរបស់គណៈគ្រប់គ្រង** |
| ១ | ការអប់រំកុមារតូច... | ការអភិវឌ្ឍចំណេះដឹងរបស់កុមារតូច |
| ២ | ការផ្ទេរសេវាការអប់រំកុមារតូច... | ការបង្កិតសេវាអប់រំទៅជិតអ្នកទទួលសេវា |
| ៣ | ការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង-ស្រុក... | កំណែទម្រង់វិមជ្ឍការ និងសហវិមជ្ឈការក្នុងវិស័យអប់រំ |
| ៤ | គោលបំណងនៃការផ្ទេរសេវាការអប់រំកុមារតូច... | ពង្រីកសេវាអប់រំកុមារតូច<br>បង្កើនស្វ័យភាពនៃការគ្រប់គ្រងសាលា<br>ធានាប្រសិទ្ធភាពអប់រំនៅមត្តេយ្យសិក្សា |
| ៥ | យន្តការនៃការផ្ទេរសេវាការអប់រំកុមារតូច... | ការអនុវត្ត និងពិនិត្យតាមដាន |
| ៦ | ការផ្ទេរសេវាការអប់រំកុមារតូចក្នុងការលើកកម្ពស់គុណភាពអប់រំ... | បង្កើនការចុះឈ្មោះចូលរៀនរបស់សិស្ស<br>អភិវឌ្ឍវិធីសាស្ត្របង្រៀននិងរៀន<br>ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង |
| ៧ | ប្រសិទ្ធភាពនៃការផ្ទេរសេវាការអប់រំកុមារតូច... | ជំរុញលើកទឹកចិត្តការចូលរួមពីភាគីពាក់ព័ន្ធ<br>ពង្រឹងការគ្រប់គ្រងសេវាអប់រំ<br>អភិវឌ្ឍនិងលើកកម្ពស់គុណភាពអប់រំ |
| ៨ | សារៈប្រយោជន៍នៃការផ្ទេរសេវាការអប់រំកុមារតូច... | ធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ<br>ផ្សព្វផ្សាយសេវាអប់រំឱ្យបានទូលំទូលាយ<br>ធានាប្រសិទ្ធភាព និងគុណភាពអប់រំ<br>ស្វែងរកដៃគូអភិវឌ្ឍដើម្បីគាំទ្រសេវាអប់រំ |

តារាង ៤.២ បានបង្ហាញពីទស្សនៈរបស់គ្រូបង្រៀនចំពោះការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។ លទ្ធផលស្រាវជ្រាវបានង្ហាញថា ការអប់រំកុមារតូច សំដៅលើកុមារតូចទទួលបានការអប់រំនៅសាលា ថ្នាក់មត្តេយ្យសិក្សា។ យោងតាមលទ្ធផលស្រាវជ្រាវដែលបានបង្ហាញក្នុងតារាង ៤.២ ការផ្ទេរសេវាអប់រំកុមារតូច មានន័យថា ពង្រឹងការអប់រំនៅមត្តេយ្យសិក្សា។ ការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក គឺការផ្ទេរការអប់រំ និងការសម្រេចចិត្តមកថ្នាក់ក្រោមបង្គាប់។ គោលបំណងនៃការផ្ទេរសេវាការអប់រំកុមារតូច ជាការផ្ទេរការទទួលខុសត្រូវ និងការសម្រេចចិត្តពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ។ យន្តការនៃការផ្ទេរសេវាការអប់រំ បង្កើនផ្សព្វផ្សាយព័ត៌មានអប់រំ ពង្រឹងការងារបង្រៀននិងរៀន និងលើកកម្ពស់គុណភាពអប់រំ។

ការផ្ទេរសេវាការអប់រំកុមារតូចក្នុងការលើកកម្ពស់គុណភាពអប់រំរួមមាន បង្កើនការចូលរៀនរបស់កុមារតូច និងអភិវឌ្ឍគុណភាពអប់រំ។ ប្រសិទ្ធភាពនៃការផ្ទេរសេវាការអប់រំកុមារតូច រួមចំណែកលើកកម្ពស់ការបង្រៀននិងរៀន និងគាំទ្រសេវាអប់រំនៅមត្តេយ្យសិក្សា។ សារៈប្រយោជន៍នៃការផ្ទេរសេវាការអប់រំកុមារតូច រួមមានកែលម្អប្រព័ន្ធអប់រំ ពង្រីកនិងផ្តល់សេវាអប់រំដល់កុមារតូច និងបង្កើនការចូលរួមនិងគាំទ្រ។

*តារាង ៤.២ ទស្សនៈគ្រូបង្រៀនចំពោះការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក*

| | **ខ្លឹមសារ** | **ចម្លើយរបស់គ្រូបង្រៀន** |
|---|---|---|
| ១ | ការអប់រំកុមារតូច... | កុមារតូចទទួលបានការអប់រំ |
| ២ | ការផ្ទេរសេវាការអប់រំកុមារតូច... | ពង្រឹងការអប់រំនៅមត្តេយ្យសិក្សា |
| ៣ | ការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក... | ការផ្ទេរការគ្រប់គ្រង និងការសម្រេចចិត្តមកថ្នាក់ក្រោមបង្គាប់ |
| ៤ | គោលបំណងនៃការផ្ទេរសេវាការអប់រំកុមារតូច... | ការផ្ទេរការទទួលខុសត្រូវ និងការសម្រេចចិត្តពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ |
| ៥ | យន្តការនៃការផ្ទេរសេវាការអប់រំកុមារតូច... | ផ្សព្វផ្សាយព័ត៌មានអប់រំ<br>ពង្រឹងការងារបង្រៀន និងរៀន<br>លើកកម្ពស់គុណភាពអប់រំ |
| ៦ | ការផ្ទេរសេវាការអប់រំកុមារតូចក្នុងការលើកកម្ពស់គុណភាពអប់រំ... | បង្កើនការចូលរៀនរបស់កុមារតូច<br>អភិវឌ្ឍគុណភាពអប់រំ |
| ៧ | ប្រសិទ្ធភាពនៃការផ្ទេរសេវាការអប់រំកុមារតូច... | លើកកម្ពស់ការបង្រៀននិងរៀន<br>គាំទ្រសេវាអប់រំនៅមត្តេយ្យសិក្សា |
| ៨ | សារៈប្រយោជន៍នៃការផ្ទេរសេវាការអប់រំកុមារតូច... | កែលម្អប្រព័ន្ធអប់រំ<br>ពង្រីក និងផ្តល់សេវាអប់រំដល់កុមារតូច<br>បង្កើនការចូលរួម និងគាំទ្រ |

តារាង ៤.៣ បានបង្ហាញពីទស្សនៈរបស់មាតាបិតា ឬអ្នកអាណាព្យាបាលកុមារ ចំពោះការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។ លទ្ធផលស្រាវជ្រាវបានង្ហាញថា ការអប់រំកុមារតូច សំដៅលើការបញ្ជូនកូនចៅទៅសាលា ថ្នាក់មត្តេយ្យសិក្សា។ យោងតាមលទ្ធផលស្រាវជ្រាវដែលបានបង្ហាញក្នុងតារាង ៤.៣ ការផ្ទេរសេវាអប់រំកុមារតូច គឺការផ្តល់សេវាមត្តេយ្យសិក្សា។ ការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក មានន័យថាការប្រគល់ការ

គ្រប់គ្រងសេវាអប់រំទៅរដ្ឋបាល/ស្រុក។ គោលបំណងនៃការផ្ទេរសេវាការអប់រំកុមារតូច គឺត្រៀមចំណេះដឹងកុមារសម្រាប់ការចូលរៀន និងបង្វិតសេវាអប់រំទៅមូលដ្ឋាន។ យន្តការនៃការផ្ទេរសេវាការអប់រំកុមារតូច រួមមានពង្រឹងការផ្សព្វផ្សាយសេវាអប់រំកុមារតូច។

ការផ្ទេរសេវាការអប់រំកុមារតូច ពង្រឹងការផ្សព្វផ្សាយេសវាអប់រំកុមារតូច។ ការផ្ទេរសេវាការអប់រំកុមារតូចក្នុងការលើកកម្ពស់គុណភាពអប់រំ រួមមានកុមារមានចំណេះដឹង និងអភិវឌ្ឍនៃការគិត និងកុមារអភិវឌ្ឍរាងកាយ។ ប្រសិទ្ធភាពនៃការផ្ទេរសេវាការអប់រំកុមារតូច គឺជានាគុណភាពនៃការបង្រៀននិងរៀន។ សារៈប្រយោជន៍នៃការផ្ទេរសេវាការអប់រំកុមារតូច ជំរុញការចូលរួមពីភាគីពាក់ព័ន្ធ និងបង្កភាពងាយស្រួលដល់កុមារក្នុងការចូលរៀន។

*តារាង ៤.៣ ទស្សនៈមាតាបិតា ឬអ្នកអាណាព្យាលសិស្សចំពោះការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក*

| ខ្លឹមសារ | | ចម្លើយរបស់មាតាបិតា ឬអ្នកអាណាព្យាលកុមារ |
|---|---|---|
| ១ | ការអប់រំកុមារតូចជា... | ការបញ្ជូនកូនឬចៅទៅមត្តេយ្យសិក្សា |
| ២ | ការផ្ទេរសេវាការអប់រំកុមារតូច ... | ការផ្តល់សេវាមត្តេយ្យសិក្សា |
| ៣ | ការផ្ទេរសេវាការអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក... | ការប្រគល់ការគ្រប់គ្រងសេវាអប់រំ ទៅរដ្ឋបាលស្រុក |
| ៤ | គោលបំណងនៃការផ្ទេរសេវាការអប់រំកុមារតូច... | ត្រៀមចំណេះដឹងកុមារសម្រាប់ការចូលរៀន បង្វិតសេវាអប់រំទៅមូលដ្ឋាន |
| ៥ | យន្តការនៃការផ្ទេរសេវាការអប់រំកុមារតូច... | ពង្រឹងការផ្សព្វផ្សាយសេវាអប់រំកុមារតូច |
| ៦ | ការផ្ទេរសេវាការអប់រំកុមារតូចក្នុងការលើកកម្ពស់គុណភាពអប់រំ... | កុមារមានចំណេះដឹង និងអភិវឌ្ឍនៃការគិត កុមារអភិវឌ្ឍរាងកាយ |
| ៧ | ប្រសិទ្ធភាពនៃការផ្ទេរសេវាការអប់រំកុមារតូច... | ជានាគុណភាពនៃការបង្រៀននិងរៀន |
| ៨ | សារៈប្រយោជន៍នៃការផ្ទេរសេវាការអប់រំកុមារតូច... | ជំរុញការចូលរួមពីភាគីពាក់ព័ន្ធ បង្កភាពងាយស្រួលដល់កុមារក្នុងការចូលរៀន |

### ៤.១.២ ការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា

តារាង ៤.៤ បានបង្ហាញពីទស្សនៈរបស់គណៈគ្រប់គ្រងចំពោះការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា។ លទ្ធផលស្រាវជ្រាវបានង្ហាញថា មត្តេយ្យសិក្សា សំដៅលើកន្លែងផ្តល់ចំណេះដឹង។ យោងតាមលទ្ធផល

ស្រាវជ្រាវដែលបានបង្ហាញក្នុងតារាង ៤.៤ ការគ្រប់គ្រងការអប់រំកុមារតូច គឺការដឹកនាំ និងការអនុវត្តលើការងារអប់រំកុមារតូច។ គោលបំណងនៃការគ្រប់គ្រងការអប់រំកុមារតូច ធានាប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំកុមារតូច។ តួនាទីគណៈគ្រប់គ្រងចំពោះការផ្ទេរសេវាអប់រំកុមារតូច រួមមានរៀបចំផែនការ ផ្សព្វផ្សាយ អនុវត្ត និងជំរុញនិងលើកទឹកចិត្តការចូលរួម។ ផែនការសកម្មភាពនៃការគ្រប់គ្រងការអប់រំកុមារតូច មានការផ្សព្វផ្សាយ អនុវត្ត និងតាមដាននិងវាយតម្លៃការអប់រំនៅមត្តេយ្យសិក្សា។

*តារាង ៤.៤ ទស្សនៈគណៈគ្រប់គ្រងចំពោះការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា*

| | **ខ្លឹមសារ** | **ចម្លើយរបស់គណៈគ្រប់គ្រង** |
|---|---|---|
| ១ | មត្តេយ្យសិក្សា ... | កន្លែងផ្តល់ចំណេះដឹងដំបូង |
| ២ | ការគ្រប់គ្រងការអប់រំកុមារតូច ... | ការដឹកនាំ និងការអនុវត្តលើការងារអប់រំកុមារតូច |
| ៣ | គោលបំណងនៃការគ្រប់គ្រងការអប់រំកុមារតូច... | ធានាប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំទៅកុមារ |
| ៤ | តួនាទីគណៈគ្រប់គ្រងចំពោះការផ្ទេរសេវាអប់រំកុមារតូច... | រៀបចំផែនការ ផ្សព្វផ្សាយ អនុវត្ត និងជំរុញនិងលើកទឹកចិត្តការរចូលរួម |
| ៥ | ផែនការសកម្មភាពនៃការគ្រប់គ្រងការអប់រំកុមារតូច ... | ការផ្សព្វផ្សាយ អនុវត្ត និងតាមដាននិងវាយតម្លៃការអប់រំនៅមត្តេយ្យសិក្សា |
| ៦ | យុទ្ធសាស្ត្រនៃការគ្រប់គ្រងការអប់រំកុមារតូច... | ការពង្រឹងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ធានាគុណភាព និងប្រសិទ្ធភាពអប់រំ |
| ៧ | ការគ្រប់គ្រងការអប់រំកុមារតូចឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣... | អភិវឌ្ឍធនធានមនុស្ស<br>លើកកម្ពស់គុណភាពអប់រំ<br>លើកទឹកចិត្តការចូលរួមពីភាគីពាក់ព័ន្ធ |
| ៨ | ប្រសិទ្ធភាពនៃការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា... | មានចក្ខុវិស័យ បេសកម្មកម្ម និងគោលបំណងច្បាស់លាស់លើការគ្រប់គ្រងការអប់រំកុមារតូច |

យុទ្ធសាស្ត្រនៃការគ្រប់គ្រងការអប់រំកុមារតូច ការពង្រឹងការគ្រប់គ្រងការគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុ និងធានាគុណភាពនិងប្រសិទ្ធភាពអប់រំ។  ការគ្រប់គ្រងការអប់រំកុមារតូចឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ មានចក្ខុវិស័យ បេសកម្ម និងគោលបំណងច្បាស់លាស់លើការគ្រប់គ្រងការអប់រំកុមារតូច។

តារាង ៤.៥ បានបង្ហាញពីទស្សនៈរបស់គ្រូបង្រៀនចំពោះការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា។ លទ្ធផលស្រាវជ្រាវបានង្ហាញថា មត្តេយ្យសិក្សា សំដៅលើថ្នាលសេវាអប់រំកុមារតូច។ យោងតាមលទ្ធផលស្រាវជ្រាវដែលបានបង្ហាញក្នុងតារាង ៤.៥ ការគ្រប់គ្រងការអប់រំកុមារតូច គឺការដឹកនាំ និងការអនុវត្តលើការងារអប់រំកុមារតូច។ គោលបំណងនៃការគ្រប់គ្រងការអប់រំកុមារតូច ជានាប្រសិទ្ធភាពនៃការបង្រៀននិងរៀន។ តួនាទីគណៈគ្រប់គ្រងចំពោះការផ្ទេរសេវាអប់រំកុមារតូច គឺរៀបចំផែនការ នៃការបង្រៀននិងរៀន។ ផែនការសកម្មភាពនៃការគ្រប់គ្រងការអប់រំកុមារតូច ការផ្សព្វផ្សាយ អនុវត្ត និងតាមដាននិងវាយតម្លៃការអប់រំនៅមត្តេយ្យសិក្សា។

*តារាង ៤.៥ ទស្សនៈគ្រូបង្រៀនចំពោះការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា*

| | **ខ្លឹមសារ** | **ចម្លើយរបស់គ្រូបង្រៀន** |
|---|---|---|
| ១ | មត្តេយ្យសិក្សា ... | ថ្នាលសេវាអប់រំកុមារតូច |
| ២ | ការគ្រប់គ្រងការអប់រំកុមារតូច ... | ការដឹកនាំ និងការអនុវត្តលើការងារបង្រៀននិងរៀន |
| ៣ | គោលបំណងនៃការគ្រប់គ្រងការអប់រំកុមារតូច... | ជានាប្រសិទ្ធភាពនៃបង្រៀននិងរៀន |
| ៤ | តួនាទីគណៈគ្រប់គ្រងចំពោះការផ្ទេរសេវាអប់រំកុមារតូច... | រៀបចំផែនការ នៃការបង្រៀននិងរៀន |
| ៥ | ផែនការសកម្មភាពនៃការគ្រប់គ្រងការអប់រំកុមារតូច ... | ការផ្សព្វផ្សាយ លទ្ធផលសិក្សារបស់កុមារ |
| ៦ | យុទ្ធសាស្ត្រនៃការគ្រប់គ្រងការអប់រំកុមារតូច... | ការពង្រឹងការគ្រប់គ្រងរដ្ឋបាលរដ្ឋបាលថ្នាក់រៀន |
| ៧ | ការគ្រប់គ្រងការអប់រំកុមារតូចឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣... | អភិវឌ្ឍសមត្ថភាពចំណេះដឹងកុមារ<br>លើកកម្ពស់គុណភាពបង្រៀននិងរៀន<br>លើកទឹកចិត្តការចូលរួមគាំទ្ររបស់សហគមន៍ |
| ៨ | ប្រសិទ្ធភាពនៃការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា... | លទ្ធផលរំពឹងទុករបស់កុមារតាមមុខវិជ្ជានីមួយៗ |

យុទ្ធសាស្ត្រនៃការគ្រប់គ្រងការអប់រំកុមារតូច មានការពង្រឹងការគ្រប់គ្រងការគ្រប់គ្រងរដ្ឋបាលនិងហិរញ្ញវត្ថុ និងជានាគុណភាពនិងប្រសិទ្ធភាពអប់រំ។ ការគ្រប់គ្រងការអប់រំកុមារតូចឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ក្នុងការអភិវឌ្ឍចំណេះដឹងកុមារ លើកកម្ពស់គុណភាពបង្រៀននិងរៀន និងលើកទឹកចិត្តសហគមន៍។ ប្រសិទ្ធភាពនៃការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា ឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុករបស់កុមារតាមមុខវិជ្ជានីមួយៗ

តារាង ៤.៦ បានបង្ហាញពីទស្សនៈរបស់មាតាបិតា ឬអ្នកអាណាព្យាសិស្សចំពោះការអប់រំកុមារតូចនៅមត្តេយ្យសិក្សា។ លទ្ធផលស្រាវជ្រាវបានង្ហាញថា មត្តេយ្យសិក្សា សំដៅលើការចូលរៀន និងបន្សាំកូនទៅនឹងសាលារៀន។ យោងតាមលទ្ធផលស្រាវជ្រាវដែលបានបង្ហាញក្នុងតារាង ៤.៦ ការគ្រប់គ្រងការអប់រំកុមារតូច គឺការអនុវត្តលើការបង្រៀននិងរៀន។ គោលបំណងនៃការគ្រប់គ្រងការអប់រំកុមារតូច ការបង្រៀននិងរៀនមានស្ថេរភាព។ តួនាទីគណៈគ្រប់គ្រងចំពោះការផ្ទេរសេវាអប់រំកុមារតូច គ្រប់គ្រងគ្រូបង្រៀននិងសិស្ស។ ផែនការសកម្មភាពនៃការគ្រប់គ្រងការអប់រំកុមារតូច គៀងគរធនធានដើម្បីគាំទ្រ។ យុទ្ធសាស្ត្រនៃការគ្រប់គ្រងការអប់រំកុមារតូច ពង្រឹងការគ្រប់គ្រងការគ្រប់គ្រងសាលារៀន។

*តារាង ៤.៦ ទស្សនៈមាតាបិតា ឬអ្នកអាណាព្យាបាសិស្សចំពោះការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា*

| | **ខ្លឹមសារ** | **ចម្លើយរបស់មាតាបិតា ឬអ្នកអាណាព្យាបាលកុមារ** |
|---|---|---|
| ១ | មត្តេយ្យសិក្សា ... | ការចូលរៀនដំបូង និងបន្សាំកូនទៅនឹងសាលា |
| ២ | ការគ្រប់គ្រងការអប់រំកុមារតូច ... | ការអនុវត្តលើការបង្រៀននិងរៀន |
| ៣ | គោលបំណងនៃការគ្រប់គ្រងការអប់រំកុមារតូច... | ការបង្រៀននិងរៀនមានស្ថេរភាព |
| ៤ | តួនាទីគណៈគ្រប់គ្រងចំពោះការផ្ទេរសេវាអប់រំកុមារតូច... | គ្រប់គ្រងគ្រូបង្រៀន និងសិស្ស |
| ៥ | ផែនការសកម្មភាពនៃការគ្រប់គ្រងការអប់រំកុមារតូច ... | គៀងគរធនធានគាំទ្រ |
| ៦ | យុទ្ធសាស្ត្រនៃការគ្រប់គ្រងការអប់រំកុមារតូច... | ការពង្រឹងការគ្រប់គ្រងសាលារៀន |
| ៧ | ការគ្រប់គ្រងការអប់រំកុមារតូចឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣... | ប្រមូលកុមារចូលរៀន |
| ៨ | ប្រសិទ្ធភាពនៃការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា... | កុមារមានចំណេះដឹង និងសុខភាពល្អ |

ការគ្រប់គ្រងការអប់រំកុមារតូចឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ មានការប្រមូលកុមារចូលរៀន។ ប្រសិទ្ធភាពនៃការគ្រប់គ្រងការអប់រំកុមារតូចនៅមត្តេយ្យសិក្សា កុមារមានចំណេះដឹង និងសុខភាពល្អ។

### ៤.១.៣ ផលជះនៃការផ្ទេរអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក

តារាង ៤.៧ បានបង្ហាញពីភាគរយនៃផលជះលើការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។ យោងតាមទស្សនៈអ្នកគណៈគ្រប់គ្រងចំពោះផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក អ្នកចូលរួមឆ្លើយ

ចំនួន៧នាក់ ស្មើនឹង៨,៤ភាគរយ ដែលយល់ថាបានផ្តល់ភាពងាយស្រួលដល់កុមារក្នុងការចូលរៀន។ អ្នកចូលរួមឆ្លើយចំនួន១០នាក់ ស្មើនឹង១២,១ភាគរយ ដែលយល់ថាបានបង្កើនការចុះឈ្មោះចូលរៀន។ អ្នកចូលរួមឆ្លើយចំនួន១០នាក់ ស្មើនឹង១២,៤ភាគរយ ដែលយល់ថាបានបង្ខិតសេវាអប់រំទៅជិតអ្នកទទួលសេវាអប់រំ។

*តារាង ៤.៧ ទស្សនៈគណៈគ្រប់គ្រង ចំពោះផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក*

| ខ្លឹមសារ | | ចំនួន | ភាគរយ (%) |
|---|---|---|---|
| ១ | ការផ្តល់ភាពងាយស្រួលកុមារក្នុងការរៀន | ៧ | ៨,៤ |
| ២ | ការបង្កើនការចុះឈ្មោះចូលរៀនរបស់កុមារ | ១០ | ១២,១ |
| ៣ | ការបង្ខិតសេវាអប់រំទៅជិតអ្នកទទួលសេវាអប់រំ | ១០ | ១២,៤ |
| ៤ | ការអភិវឌ្ឍវិធីសាស្ត្របង្រៀន និងរៀន | ៧ | ៨,៧ |
| ៥ | ការបង្កើនការចូលរួម និងគាំទ្រពីភាគីពាក់ព័ន្ធ | ១០ | ១១,៨ |
| ៦ | ការលើកកម្ពស់គុណភាពអប់រំ | ១០ | ១២,១ |
| ៧ | ការអភិវឌ្ឍការគ្រប់គ្រងវិស័យអប់រំ | ៩ | ១១,២ |
| ៨ | ការបង្កើតគោលនយោបាយវិស័យអប់រំ | ៩ | ១០,៧ |
| ៩ | ការអភិវឌ្ឍធនធានមនុស្ស | ១០ | ១២,៤ |
| សរុប | | ៨១ | ១០០ |

អ្នកចូលរួមឆ្លើយចំនួន៧នាក់ ស្មើនឹង៨,៧ភាគរយ ដែលយល់ថាមានការអភិវឌ្ឍវិធីសាស្ត្របង្រៀននិងរៀន។ អ្នកចូលរួមឆ្លើយចំនួន១០នាក់ ស្មើនឹង១១,៨ភាគរយ ដែលយល់ថាបានបង្កើនការចូលរួម និងគាំទ្រពីភាគីពាក់ព័ន្ធ។ អ្នកចូលរួមឆ្លើយចំនួន១០នាក់ ស្មើនឹង១២,១ភាគរយ ដែលយល់ថាបានលើកកម្ពស់គុណភាពអប់រំ។ អ្នកចូលរួមឆ្លើយចំនួន៩នាក់ ស្មើនឹង១១,២ភាគរយ ដែលយល់ថាបានអភិវឌ្ឍការគ្រប់គ្រងវិស័យអប់រំ។ អ្នកចូលរួមឆ្លើយចំនួន៩នាក់ ស្មើនឹង១១,២ភាគរយ ដែលយល់ថាការបង្កើតគោលនយោបាយវិស័យអប់រំ។ អ្នកចូលរួមឆ្លើយចំនួន១០នាក់ ស្មើនឹង១២,៤ភាគរយ ដែលយល់ថាបានអភិវឌ្ឍធនធានមនុស្ស។

តារាង ៤.៨ បានបង្ហាញពីភាគរយនៃផលជះលើការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។ យោងតាមទស្សនៈរបស់គ្រូបង្រៀន ចំពោះផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក អ្នកចូលរួមឆ្លើយចំនួន១៩នាក់ ស្មើនឹង១២,៦ភាគរយ ដែលយល់ថាបានផ្តល់ភាពងាយស្រួលដល់កុមារក្នុងការចូលរៀន។ អ្នកចូលរួមឆ្លើយចំនួន២០នាក់ ស្មើនឹង១៣ភាគរយ ដែលយល់ថាបានបង្កើនការចុះឈ្មោះចូលរៀន។ អ្នកចូលរួមឆ្លើយចំនួន

១៩នាក់ ស្មើនឹង១២,៧ភាគរយ ដែលយល់ថាបានបង្និតសេវាអប់រំទៅជិតអ្នកទទួលសេវាអប់រំ។ អ្នកចូលរួមឆ្លើយចំនួន១២នាក់ ស្មើនឹង៨,២ភាគរយ ដែលយល់ថាមានការអភិវឌ្ឍវិធីសាស្ត្របង្រៀននិងរៀន។ អ្នកចូលរួមឆ្លើយចំនួន១៨នាក់ ស្មើនឹង១១,៦ភាគរយ ដែលយល់ថាបានបង្កើនការចូលរួម និងគាំទ្រពីភាគីពាក់ព័ន្ធ។ អ្នកចូលរួមឆ្លើយចំនួន១៦នាក់ ស្មើនឹង១០,៧ភាគរយ ដែលយល់ថាបានលើកកម្ពស់គុណភាពអប់រំ។ អ្នកចូលរួមឆ្លើយចំនួន១៦នាក់ ស្មើនឹង១០,២ភាគរយ ដែលយល់ថាបានអភិវឌ្ឍការគ្រប់គ្រងវិស័យអប់រំ។ អ្នកចូលរួមឆ្លើយចំនួន១៤នាក់ ស្មើនឹង៩,២ភាគរយ ដែលយល់ថាការបង្កើតគោលនយោបាយវិស័យអប់រំ។ អ្នកចូលរួមឆ្លើយចំនួន១៨នាក់ ស្មើនឹង១១,៨ភាគរយ ដែលយល់ថាបានអភិវឌ្ឍធនធានមនុស្ស។

*តារាង ៤.៨ ទស្សនៈគ្រូបង្រៀន ចំពោះផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក*

| ខ្លឹមសារ | | ចំនួន | ភាគរយ (%) |
|---|---|---|---|
| ១ | ការផ្ដល់ភាពងាយស្រួលកុមារក្នុងការរៀន | ១៩ | ១២,៦ |
| ២ | ការបង្កើនការចុះឈ្មោះចូលរៀនរបស់កុមារ | ២០ | ១៣,០ |
| ៣ | ការបង្និតសេវាអប់រំទៅជិតអ្នកទទួលសេវាអប់រំ | ១៩ | ១២,៧ |
| ៤ | ការអភិវឌ្ឍវិធីសាស្ត្របង្រៀន និងរៀន | ១២ | ៨,២ |
| ៥ | ការបង្កើនការចូលរួម និងគាំទ្រពីភាគីពាក់ព័ន្ធ | ១៨ | ១១,៦ |
| ៦ | ការលើកកម្ពស់គុណភាពអប់រំ | ១៦ | ១០,៧ |
| ៧ | ការអភិវឌ្ឍការគ្រប់គ្រងវិស័យអប់រំ | ១៦ | ១០,២ |
| ៨ | ការបង្កើតគោលនយោបាយវិស័យអប់រំ | ១៤ | ៩,២ |
| ៩ | ការអភិវឌ្ឍធនធានមនុស្ស | ១៨ | ១១,៨ |
| **សរុប** | | **១៥២** | **១០០** |

តារាង ៤.៩ បានបង្ហាញពីភាគរយនៃផលជះលើការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក។ យោងតាមទស្សនៈរបស់មាតាបិតា ឬអ្នកអាណាព្យាបាល ចំពោះផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក អ្នកចូលរួមឆ្លើយចំនួន២៧នាក់ ស្មើនឹង១៤ភាគរយ ដែលយល់ថាបានផ្ដល់ភាពងាយស្រួលដល់កុមារក្នុងការចូលរៀន។ អ្នកចូលរួមឆ្លើយចំនួន២៨នាក់ ស្មើនឹង១៤,២ភាគរយ ដែលយល់ថាបានបង្កើនការចុះឈ្មោះចូលរៀន។ អ្នកចូលរួមឆ្លើយចំនួន២៧នាក់ ស្មើនឹង១៣,៨ភាគរយ ដែលយល់ថាបានបង្និតសេវាអប់រំទៅជិតអ្នកទទួលសេវាអប់រំ។ អ្នកចូលរួមឆ្លើយចំនួន១៨នាក់ ស្មើនឹង៩ភាគរយ ដែលយល់ថាមានការអភិវឌ្ឍវិធីសាស្ត្របង្រៀននិងរៀន។ អ្នកចូលរួមឆ្លើយ

ចំនួន២១នាក់ ស្មើនឹង១០,៧ភាគរយ ដែលយល់ថាបានបង្កើនការចូលរួម និងគាំទ្រពីភាគីពាក់ព័ន្ធ។ អ្នកចូលរួមឆ្លើយចំនួន១៨នាក់ ស្មើនឹង៩,២ភាគរយ ដែលយល់ថាបានលើកកម្ពស់គុណភាពអប់រំ។ អ្នកចូលរួមឆ្លើយចំនួន១៨នាក់ ស្មើនឹង៩,៣ភាគរយ ដែលយល់ថាបានអភិវឌ្ឍការគ្រប់គ្រងវិស័យអប់រំ។ អ្នកចូលរួមឆ្លើយចំនួន១៨នាក់ ស្មើនឹង ៩,៣ភាគរយ ដែលយល់ថាការបង្កើតគោលនយោបាយវិស័យអប់រំ។ អ្នកចូលរួមឆ្លើយចំនួន២០នាក់ ស្មើនឹង១០,៥ ភាគរយ ដែលយល់ថាបានអភិវឌ្ឍធនធានមនុស្ស។

*តារាង ៤.៩ ទស្សនៈមាតាបិតា ឬអ្នកអាណាព្យាបាលសិស្សចំពោះផលជះការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក*

| | ខ្លឹមសារ | ចំនួន | ភាគរយ (%) |
|---|---|---|---|
| ១ | ការផ្តល់ភាពងាយស្រួលកុមារក្នុងការរៀន | ២៧ | ១៤,០ |
| ២ | ការបង្កើនការចុះឈ្មោះចូលរៀនរបស់កុមារ | ២៨ | ១៤,២ |
| ៣ | ការបង្វិតសេវាអប់រំទៅជិតអ្នកទទួលសេវាអប់រំ | ២៧ | ១៣,៨ |
| ៤ | ការអភិវឌ្ឍវិធីសាស្រ្តបង្រៀន និងរៀន | ១៨ | ៩,០ |
| ៥ | ការបង្កើនការចូលរួម និងគាំទ្រពីភាគីពាក់ព័ន្ធ | ២១ | ១០,៧ |
| ៦ | ការលើកកម្ពស់គុណភាពអប់រំ | ១៨ | ៩,២ |
| ៧ | ការអភិវឌ្ឍការគ្រប់គ្រងវិស័យអប់រំ | ១៨ | ៩,៣ |
| ៨ | ការបង្កើតគោលនយោបាយវិស័យអប់រំ | ១៨ | ៩,៣ |
| ៩ | ការអភិវឌ្ឍធនធានមនុស្ស | ២០ | ១០,៥ |
| **សរុប** | | **១៩៥** | **១០០** |

## ៤.២ ការពិភាក្សាលើលទ្ធផលស្រាវជ្រាវ

### ៤.២.១ យន្តការនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង-ស្រុក

យោងតាមលទ្ធផលស្រាវជ្រាវ ដែលបានបកស្រាយក្នុងចំណុច៤.១.១ នៃជំពូក៤ ការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក គឺជាការបង្វិតសេវាអប់រំទៅជិតអ្នកទទួលសេវាអប់រំ។ ការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង-ស្រុក មានសារៈសំខាន់ណាស់សម្រាប់ការបង្កើតយន្តការ និងគោលនយោបាយអប់រំ(ក្រសួងអយក, ២០១៩) នៃការគ្រប់គ្រងសេវាអប់រំនៅថ្នាក់ក្រោមជាតិ ដើម្បីអភិវឌ្ឍការងារដឹកនាំ និងគ្រប់គ្រងសាលារៀន។ ការផ្ទេរសេវាអប់រំកុមារតូច ជួយលើកកម្ពស់គុណភាពអប់រំ និង អភិវឌ្ឍវិធីសាស្រ្តបង្រៀន និងរៀន។ ការផ្ទេរសេវាអប់រំកុមារតូច ជាការឆ្លុះ

បញ្ចាំងការទទួលខុសត្រូវក្នុងការអភិវឌ្ឍមូលដ្ឋានរួមមានការអភិវឌ្ឍធនធានមនុស្ស លើកកម្ពស់ការចូលរួមក្នុងសកម្មភាពការងារអប់រំ និងការគាំទ្រគ្នាទៅវិញទៅមករវាងថ្នាក់ជាតិ ទៅថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តស្តង់ដាអប្បរមាសេវាមានការគ្រប់គ្រង (បុគ្គលិកអប់រំ ថវិកា និងហេដ្ឋារចនាសម្ព័ន្ធអប់រំ) យន្តការចូលរួមរបស់សហគមន៍ និងលទ្ធផលសិក្សារបស់សិស្ស។

យន្តការនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក គឺជាការផ្ទេរការអនុវត្ត និងការពិនិត្យតាមដានសេវាអប់រំកុមារតូចពីថ្នាក់ជាតិ ទៅថ្នាក់ក្រោមជាតិ តាមរយៈយន្តការនេះយើងអាចអន្តរាគមន៍អភិវឌ្ឍសមត្ថភាពដែលឆ្លើយតបនឹងតម្រូវការសេវាអប់រំកុមារតូច។

ការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក គឺជាការផ្សព្វផ្សាយនូវសេវាអប់រំកុមារតូចឱ្យបានទូលំទូលាយ និងជាមូលដ្ឋានគ្រឹះក្នុងការធ្វើកំណែទម្រង់សេវាអប់រំតាមបែបវិមជ្ឈការ និងសហវិមជ្ឈការ និងជាកត្តាជំរុញការសម្របសម្រួលរវាងតួអង្គពាក់ព័ន្ធនានា សម្រាប់ការអនុវត្តសេវាអប់រំកុមារតូចទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ៤.២.២ យុទ្ធសាស្ត្រនៃការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា

យោងតាមលទ្ធផលស្រាវជ្រាវដែលបានបកស្រាយក្នុងចំណុច៤.១.២ នៃជំពូក៤ ការគ្រប់គ្រងសេវាអប់រំកុមារតូចនៅមត្តេយ្យសិក្សា សំដៅការរៀបចំផែនការ អនុវត្ត និងតាមដាន និងវាយតម្លៃលើដំណើរការផ្តល់សេវាអប់រំកុមារតូចនៅមូលដ្ឋាន។ ការគ្រប់គ្រងសេវាអប់រំកុមារតូច គឺជានាប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំ និងកម្មវិធីអភិវឌ្ឍមូលដ្ឋានជាផែនការដែលមានការចូលរួមរៀបចំ និងចូលរួមអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធនៅក្នុងភូមិសាស្ត្រ នៃរដ្ឋបាលក្រុង/ស្រុក និងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់បញ្ជាក់ពីគណនេយ្យភាពចំពោះសហគមន៍ និងរដ្ឋបាលក្រុង/ស្រុក។

យុទ្ធសាស្ត្រនៃការគ្រប់គ្រងសេវាអប់រំកុមារតូច គឺពង្រឹងការងារគ្រប់គ្រងតាមសាលារៀន និងការរៀបចំលិខិតលិខិតបទដ្ឋានដែលពាក់ព័ន្ធ សម្រាប់សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងរកការគាំទ្រ នោះនាំឱ្យស្វ័យភាពនៃការគ្រប់គ្រងសេវាត្រូវបានលើកតម្កើងនូវគណនេយ្យភាពមូលដ្ឋាន ដោយសារនាំមកនូវការសម្រេចចិត្តដោយផ្តោតលើអាទិភាព គុណតម្លៃ និងសេចក្តីត្រូវការពីមូលដ្ឋាន ព្រោះថាការចូលរួមពីមាតាបិតា ឬអ្នកណាព្យាលកុមារ និងសហគមន៍ នឹងផ្តល់ដល់គ្រូបង្រៀននូវឱកាសបង្កើតឡើងនូវការប្តេជ្ញាចិត្តចំពោះកុមារ និងមាតាបិតា និងអ្នកអាណាព្យាលកុមារ។

### ៤.២.៣ សារៈសំខាន់នៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក

យោងតាមលទ្ធផលស្រាវជ្រាវដែលបានបកស្រាយក្នុងចំណុច៤.១.៣ នៃជំពូក៤ ផលជះនៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក បង្កើនលទ្ធភាពចុះឈ្មោះចូលរៀន និងបង្កភាពងាយស្រួលដល់ការចូលរៀនរបស់កុមារតូច ។ ការផ្ទេរសេវាអប់រំកុមារតូច បានជំរុញការចូលរួមគាំទ្ររបស់មាតាបិតា ឬអ្នកអាណាព្យាបាលកុមារ ក្នុងការពង្រឹងសមត្ថភាពចំណេះដឹងកុមារសម្រាប់ការចូលរៀន។

ការចូលរួមពីមាតាបិតា ឬអ្នណាព្យាលកុមារ និងសហគមន៍ ចំពោះកិច្ចការ ឬព្រឹត្តការណ៍ណាមួយរបស់សាលារៀន បានចូលរួមការទំនាក់ទំនងគ្នាដោយផ្សាភ្ជាប់គ្នា រវាងសាលារៀន ទៅនឹងសហគមន៍(អ្នកទទួលសេវា) និងចូលរួមបណ្តុះវប្បធម៌សាលារៀន ដោយការទំនាក់គ្នារវាងសិស្សនិងគ្រូ គណៈគ្រប់គ្រងសេវានិងគ្រូ និងគ្រូ និងមាតាបិតា ឬអ្នកអាណាព្យាបាលរបស់កុមារ ដែលជាកត្តាមួយល្អសម្រាប់បរិយាកាសសិក្សារៀនសូត្ររបស់កុមារ។

សារៈសំខាន់នៃការផ្ទេរសេវាអប់រំកុមារតូចទៅរដ្ឋបាលក្រុង/ស្រុក គឺការអនុវត្តសេវាអប់រំកុមារតូចមានការអភិវឌ្ឍ និងស្ថេរភាព ដែលអាចនាំទៅការគាំទ្រកម្មវិធីកំណែទម្រង់នានានឹងត្រូវបង្កើតឡើង ដើម្បីជានាបានការអនុវត្តសេវាអប់រំកុមារតូចបានទាន់ពេលវេលា ដែលចូលរួមក្នុងការងារបែបវិមជ្ឈការ និងសហវិមជ្ឈការ។

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

